កំណែលើបណ្តាញត្រូវបានរកឃើញនៅ: http://workerdiaries.org/gwdiaries/cambodia/story_html5.html




GARMENT WORKER DIARIES

## តើនរណាផលិតសំលៀកបំពាក់របស់ខ្ញុំ? របាយការណ៍មួយពីប្រទេសកម្ពុជា

យើងទាំងអស់គ្នាពាក់សំលៀកបំពាក់។ ភាគច្រើននៃសំលៀកបំពាក់ទាំងនេះ គឺត្រូវបានផលិតនៅក្នុងរោងចក្រក្នុងទ្វីបអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដោយផុតពីក្រសែភ្នែកអ្នកដែលទិញនិងពាក់សំលៀកបំពាក់ទាំងនេះ។ ដូច្នេះហើយបានជាដៃគូរបស់យើង Fashion Revolution បានលើកទឹកចិត្តឱ្យមនុស្សសួរខ្លួនឯង៖

"តើនរណាផលិតផលសំលៀកបំពាក់របស់ខ្ញុំ"។

យើងព្យាយាមឆ្លើយនឹងសំណួរនេះ ហើយបានដឹងពីជីវិតរបស់កម្មករទាំងនេះ ដោយប្រមូលទិន្នន័យអំពីស្ថានភាពសេដ្ឋកិច្ចរបស់កម្មករកាត់ដេរនៅក្នុងប្រទេសកម្ពុជា។

ដើម្បីធ្វើដូច្នេះបាន អ្នកស្រាវជ្រាវមួយក្រុមបានចុះទៅជួបកម្មករកាត់ដេរចំនួន ១៨៦នាក់ ជារៀងរាល់សប្តាហ៍សម្រាប់រយៈពេលមួយឆ្នាំ។
អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យអំពីចំនួនប្រាក់ដែលកម្មកររកបាន និងចំណាយក្នុងសប្តាហ៍នីមួយៗ ក៏ដូចជា ចំនួនម៉ោងធ្វើការដែលពួកគេបានធ្វើការ និងស្ថានភាពនៅក្នុងរោងចក្ររបស់ពួកគេ។ ពួកគេបានប្រមូល។ ទិន្នន័យផ្សេងទៀតផងដែរ ដូចជា ព័ត៌មានអំពីសន្តិសុខស្បៀង ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងសុវត្ថិភាពកន្លែងធ្វើការ។

ជំពូកទី១៖ ផ្តល់ព័ត៌មានលម្អិតអំពីទិន្នន័យអ្វីខ្លះដែលយើងប្រមូល និងវិធីនៃការប្រមូលទិន្នន័យ។

GARMENT WORKER DIARIES

## តើនរណាផលិតសំលៀកបំពាក់របស់ខ្ញុំ? របាយការណ៍មួយពីប្រទេសកម្ពុជា

យើងរៀបចំរបាយការណ៍នេះសម្រាប់អ្នកដើម្បីស្វែងយល់។
អ្នកអាចអានរបាយការណ៍នេះតាមលំដាប់លំដោយដែលបានរៀបចំ ឬអ្នកអាចប្រើប៊ូតុងរុករក (navigation) ដើម្បីរំលងទៅប្រធានបទដែលអ្នកចាប់អារម្មណ៍ខ្លាំងបំផុត។
ដោយមិនគិតពីអ្វីដែលអ្នកជ្រើសរើសយកឡើយ
អ្នកនឹងឃើញរបកគំហើញសំខាន់ៗនៅក្នុងជំពូកនីមួយៗអំពីស្ថានភាពរស់នៅរបស់កម្មករ ដូចជា៖

- ជំពូកទី២៖ ប្រាក់ឈ្នួល
    - កម្មករកម្ពុជាធ្វើការម៉ោងបន្ថែមចំនួន ៤៥%នៃសប្តាហ៍ធ្វើការរបស់ពួកគេ ហើយប្រាក់ឈ្នួលដែលទទួលបានពីម៉ោងបន្ថែម មានប្រមាណ ១០% នៃប្រាក់ចំណូលសរុបរបស់ពួកគេ។
    - ជាមធ្យម ប្រាក់ចំណូលរបស់ពួកគេគឺលើសប្រាក់ឈ្នួលអប្បបរមារបស់ប្រទេស។
- ជំពូកទី៣៖ ការចំណាយ
    - មួយចំណែកធំនៃការចំណាយរបស់កម្មករ គឺទៅលើចំណីអាហារ និងថ្លៃជួលផ្ទះសម្រាប់អ្នកដែលគ្មានផ្ទះខ្លួនឯង។
    - ចំណាយនេះធ្វើឱ្យកម្មករនៅសល់លុយតិចតួចដើម្បីចំណាយលើទំនិញ/សម្ភារ និងសេវាកម្មនានា ដែលអាចកែលម្អគុណភាពជីវិតរបស់ពួកគេ។

ចំណាំ: ដើម្បីធ្វើគ្រាប់តាមមុខងារដែលបានរៀបរាប់ជា PDF សូមប្រើផ្ទាំងចំណាំនៅខាងឆ្វេង។

GARMENT WORKER DIARIES

តើនរណាផលិតសំលៀកបំពាក់របស់ខ្ញុំ? របាយការណ៍មួយពីប្រទេសកម្ពុជា

- ជំពូកទី៤៖ ការដោះស្រាយបញ្ហាតានតឹងផ្នែកហិរញ្ញវត្ថុ
    - កម្មករអាចសន្សំប្រាក់បានតិចតួច ក្នុងករណីពួកគេត្រូវការចំណាយធំៗ ប៉ុន្តែការសន្សំនេះធ្វើឱ្យពួកគេជួបប្រទះបញ្ហាខ្លះដែរ៖
        - ៥២%នៃកម្មករ បានប្រាប់ថា ដោយសារតែពួកគេមានប្រាក់តិចតួច ពួកគេទទួលបានចំណីអាហារតិចតួចឬមិនគ្រប់គ្រាន់ក្នុងរយៈពេល១២ខែកន្លងមក។
        - កម្មករមួយចំនួនតូចបានប្រាប់ថា ពួកគេមានសុខភាពល្អ ប៉ុន្តែពួកគេបាននិយាយថា កង្វះខាតលុយគឺជាឧបសគ្គដ៏ធំក្នុងការទៅរកការថែទាំសុខភាព។
    - និយាយដោយខ្លី នេះមានន័យថា សុខភាពផ្លូវកាយរបស់កម្មករស្រូបចូលបញ្ហាតានតឹងផ្នែកហរិញ្ញវត្ថុ ជាជាងកាបូបលុយរបស់ពួកគេ។
- ជំពូកទី៥៖ ជីវិតក្នុងរោងចក្រ
    - ដោយសារតែការគំរាមកំហែងពីអគ្គិភ័យ គុណភាពខ្យល់មិនល្អ និងកម្រិតសមត្ថភាពខុសៗគ្នាក្នុងការចាកចេញពីរោងចក្រក្នុងករណីមានអាសន្ន មានតែកម្មករមួយចំនួនតូចប៉ុណ្ណោះ ដែលមានអារម្មណ៍ថាសុវត្ថិភាពនៅកន្លែងធ្វើការគ្រប់ពេលនោះ។
    - កម្មករក៏បានបញ្ជាក់ផងដែរថា មានការរើសអើងនិងបៀតបៀនទៅលើពួកគេ។

GARMENT WORKER DIARIES

# តើនរណាផលិតសំលៀកបំពាក់របស់ខ្ញុំ? របាយការណ៍មួយពីប្រទេសកម្ពុជា

ជារួម ទិន្នន័យទាំងនេះបង្ហាញថា កម្មករកាត់ដេរប្រឈមនឹងម៉ោងធ្វើការយូរ របៀបផ្តល់ប្រាក់ឈ្នួលមិនច្បាស់លាស់ ប្រាក់ឈ្នួលទាប ភាពតានតឹងផ្នែកហិរញ្ញវត្ថុ និងលក្ខខណ្ឌការងារមិនស្រួល ប៉ុន្តែពួកគេនៅតែអាចរស់បាន។ ពួកគេជំនះការលំបាក ហើយប្រកាន់ខ្ជាប់ទៅនឹងក្តីសុបិននិងបំណងប្រាថ្នារបស់ពួកគេ។ អ្នកអាចអានរឿងរ៉ាវរបស់កម្មករម្នាក់ៗនៅក្នុងប្រូហ្វែលរបស់ពួកគេក្នុងជំពូកទី ៦។

នៅពេលអ្នកអានរបាយការណ៍នេះចប់ យើងសង្ឃឹមថា អ្នកយល់ពីការលំបាករបស់មនុស្សក្នុងការផលិតសំលៀកបំពាក់ និងសំលៀកបំពាក់ប្រចាំថ្ងៃ ហើយថា អ្នកនឹងប្រើប្រាស់ព័ត៌មាននេះដើម្បីកែលម្អជីវិតរបស់កម្មករ ដោយផ្លាស់ប្តូរទីកន្លែង និងវិធីទិញសំលៀកបំពាក់របស់អ្នក ឬតាមរយៈការងារតស៊ូមតិ។ ជាកិច្ចចាប់ផ្តើម យើងលើកទឹកចិត្តឱ្យអ្នកប្រាប់ម្ចាស់ផ្លាក អំពីអ្វីដែលអ្នកបានសិក្សា ដោយចុចត្រង់នេះ (here)។ ស្ត្រីចំនួន ១៨៦នាក់ បានរួមចំណែកដល់របាយការណ៍នេះ។ សូមអរគុណអ្នក។

Eric Noggle, ប្រធានផ្នែកស្រាវជ្រាវ, MFO

Conor Gallagher, ដៃគូស្រាវជ្រាវ, MFO

Guy Stuart, នាយកប្រតិបត្តិ, MFO

ដោយចុចត្រង់នេះ

GARMENT WORKER DIARIES

## ជំពូកទី១៖ សាវតារគម្រោង

កំណត់ត្រាប្រចាំឆ្នាំរបស់កម្មករកាត់ដេរកម្ពុជា គឺជាការសិក្សារយៈពេលមួយឆ្នាំអំពីជីវិតរបស់ កម្មការនីកាត់ដេរចំនួនប្រមាណ ៥៤០នាក់ នៅក្នុងប្រទេសបង់ក្លាដែស កម្ពុជា និងឥណ្ឌា។ នៅក្នុងប្រទេសកម្ពុជា MFO បានជ្រើសរើសអ្នកចូលរួមចំនួន ១៨៦នាក់ មកពីសហគមន៍នានាក្នុងរាជធានីភ្នំពេញ និងកំពង់ស្ពឺ។ ដំណើរការជ្រើសរើសនេះ ទទួលបានសំណាកមួយដែលទំនងជាមានលក្ខណៈស្ថិរភាពជាងកម្មករកាត់ដេរកម្ពុជាជាស្ត្រីជាទូទៅ។




GARMENT WORKER DIARIES

## ដៃគូគម្រោង

ការសិក្សាអំពីកំណត់ត្រាប្រចាំថ្ងៃរបស់កម្មករកាត់ដេរត្រូវបានដឹកនាំដោយ *មីក្រូហ្វាយណាន់ អប់ផលូនីធី* Microfinance Opportunities (MFO) ដែលជាអង្គការមិនគិតកម្រៃមួយមានមូលដ្ឋាននៅក្នុងសហរដ្ឋអាមេរិក ដែលធ្វើការសិក្សាស្រាវជ្រាវលើឥរិយាបថរបស់គ្រួសារដែលមានប្រាក់ចំណូលទាប។ អង្គការ *ហ្វាស្វិន រេវ៉ូលូស្វិន* (Fashion Revolution) បានគាំទ្រដល់គម្រោងនេះ ផ្នែកតស៊ូមតិ និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយនៅមូលដ្ឋាន។ គម្រោងនេះត្រូវបានផ្តល់មូលនិធិដោយ មូលនិធិ ស៊ី និង អេ (C&A Foundation) ដែលគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញឧស្សាហកម្មសំលៀកបំពាក់ ឲ្យកែលម្អជីវិតរបស់បុរស និងស្ត្រីដែលជាអ្នកផលិតសំលៀកបំពាក់របស់យើង។

©Microfinance Opportunities. February 13, 2018.

**GARMENT WORKER DIARIES**

# តើកំណត់ត្រាប្រចាំថ្ងៃរបស់កម្មករកាត់ដេរ គឺជាអ្វី?

កំណត់ហេតុប្រចាំថ្ងៃរបស់កម្មករកាត់ដេរគឺជាគម្រោងស្រាវជ្រាវរយៈពេលមួយឆ្នាំដែលប្រមូលទិន្នន័យអំពីជីវិតរបស់កម្មករកាត់ដេរប្រហែល៥៤០ នាក់ ដែលត្រូវបានបែងចែកស្មើគ្នារវាងប្រទេសបង់ក្លាដែសកម្ពុជានិងឥណ្ឌា។ គោលដៅរបស់គម្រោងនេះគឺដើម្បីបង្ហាញពីគថភាពសេដ្ឋកិច្ចដែលកម្មកររោងចក្រជួបប្រទះ។

គម្រោងនេះបានចាប់ផ្តើមពីរដូវក្តៅ ឆ្នាំ២០១៦ រហូតដល់រដូវក្តៅឆ្នាំ២០១៧។ តាមរយៈការសម្ភាសន៍ប្រចាំសប្តាហ៍ MFO បានប្រមូលទិន្នន័យអំពីប្រាក់ចំណូលនិងការចំណាយរបស់កម្មករ ព្រមទាំងលក្ខខណ្ឌនៃការរស់នៅនិងការងាររបស់ពួកគេ។

ហេតុអ្វីជ្រើសរើសប្រទេសទាំងនេះ?

**GARMENT WORKER DIARIES**

# ហេតុអ្វីជ្រើសរើសយកប្រទេសទាំងនេះ?

ប្រទេសចំនួនបីដែល អិម.អេហ្វ.អូ និងមូលនិធិ C&A បានជ្រើសរើសយក គឺផលិតករសំលៀកបំពាក់ធំៗ ហើយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់មានសារៈសំខាន់ណាស់ចំពោះសេដ្ឋកិច្ចរបស់ប្រទេសទាំងនេះ។

យោងតាម ធនាគារពិភពលោក, បង់ក្លាដែស គឺជាប្រទេសនាំចេញធំបំផុតទីពីរនៃសំលៀកបំពាក់នៅក្នុងសកលលោក គិតជាដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ទិន្នន័យសម្រាប់ឆ្នាំថ្មីៗបំផុត ដែលមានទិន្នន័យ។ ឥណ្ឌាគឺជាប្រទេសនាំចេញធំបំផុតទីបី រីឯកម្ពុជាគឺជាប្រទេសនាំចេញបំផុតទីដប់បួន។ ការនាំចេញផលិតផលវាយនភណ្ឌសំលៀកបំពាក់តំណាងឱ្យប្រមាណ ៩០ភាគរយនៃការនាំចេញទាំងអស់នៅក្នុងប្រទេសបង់ក្លាដែស ៦៥ភាគរយនៃការនាំចេញទាំងអស់នៅក្នុងប្រទេសកម្ពុជា និង ១៤ភាគរយនៅក្នុងប្រទេសឥណ្ឌា។ បើគិតពីចំណែកនៃការនាំចេញវិញ បង់ក្លាដែលនិងកម្ពុជាមានចំណាត់ថ្នាក់ទីមួយនិងទីបី ក្នុងការពឹងផ្អែកលើសំលៀកបំពាក់និងវាយនភណ្ឌ រីឯឥណ្ឌាស្ថិតក្នុងចំណាត់ថ្នាក់ទី២៩។

បន្ថែមពីលើនេះ មូលនិធិ C&A ផ្តល់អាទិភាពដល់សកម្មភាពនៅក្នុងប្រទេសទាំងនេះ ក្នុងចំណោមប្រទេសផ្សេងៗទៀត។

ធនាគារពិភពលោក



GARMENT WORKER DIARIES

## វិធីសាស្ត្រប្រមូលទិន្នន័យ

ការសិក្សាអំពីកំណត់ត្រាប្រចាំថ្ងៃរបស់កម្មករកាត់ដេរ បានប្រើប្រាស់វិធីសាស្ត្រកំណត់ត្រាហិរញ្ញវត្ថុដែលជាវិធីសាស្ត្រស្ទង់មតិជាំណែលមួយ ដែលប្រមូលទិន្នន័យពីសកម្មភាពសេដ្ឋកិច្ចរបស់អ្នកចូលរួម រៀងរាល់សប្តាហ៍។ ក្រុមស្រាវជ្រាវរបស់យើងបានសួរសំណួរលម្អិតអំពីប្រាក់ចំណូល និងការចំណាយរបស់កម្មករ លក្ខខណ្ឌការងារ កាលវិភាគប្រចាំថ្ងៃសុខមាលភាព និងព្រឹត្តិការណ៍សំខាន់ៗ ដែលបានកើតឡើងនៅក្នុងជីវិតរបស់ពួកគេ។

បន្ថែមលើនេះក្រុមការងារស្រាវជ្រាវបានធ្វើការស្ទាបស្ទង់មតិតាមវិធី *ក្រុមសិក្សាពិភាក្សា*ចំនួនបី ជាមួយកម្មករទាំងអស់ ដែលគ្របដណ្តប់លើប្រធានបទនានា ដូចជា ចំណេះដឹងផ្នែកហិរញ្ញវត្ថុ លក្ខខណ្ឌរោងចក្រ សន្តិសុខស្បៀង និងសន្តិសុខសុខភាព។ ដើម្បីទទួលបានការយល់ដឹងកាន់តែប្រសើរអំពីបទពិសោធន៍របស់កម្មករ អិម.អេហ្វ.អូ បានធ្វើបទសម្ភាសន៍ស៊ីជម្រៅចំនួន៣៦សម្ភាសន៍ ជាមួយកម្មករក្នុងចំណោមសំណាកគំរូ។

**កំណត់ត្រាហិរញ្ញវត្ថុ**



GARMENT WORKER DIARIES

## នីតិវិធីប្រមូលទិន្នន័យ

អិម.អេហ្វ.អូ បានអនុវត្តយុទ្ធសាស្ត្រជ្រើសរើសសំណាកដែលមានប្រាំដំណាក់កាល

- ស្វែងយល់តំបន់ដែលកម្មករដាក់ដេររស់នៅ និងទំនោរការងារ
- កំណត់ទីតាំងភូមិសាស្ត្រដែលមាន កម្មករកាត់ដេរធ្វើការ
- អនុតំបន់ដែលត្រូវបានជ្រើសរើសដោយចៃដន្យ សម្រាប់ជ្រើសរើសសំណាកអ្នកចូលរួមក្នុងការសិក្សា
- អ្នកចូលរួមដែលត្រូវបានជ្រើសរើសដោយចៃដន្យនៅក្នុងតំបន់ ដោយប្រើវិធីដើរជ្រើសរើសដោយចៃដន្យ
- ពិនិត្យមើលអ្នកចូលរួម ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ទុកជាមុន ដើម្បីធានាថាពួកគេគឺជាបេក្ខជនដ៏ល្អសម្រាប់ការសិក្សានេះ។

នីតិវិធីជ្រើសរើសសំណាកលម្អិត

GARMENT WORKER DIARIES

## នីតិវិធីសំណាកជ្រើសរើសលម្អិត

ការជ្រើសរើសសំណាកកំណត់គ្រាហិរញ្ញវត្ថុ MFO

នីតិវិធីថ្លឹងថ្លែងគុណភាពបី៖

- **លទ្ធភាពដែលអាចអនុវត្តបាន៖** ដោយសារតែភាពញឹកញាប់នៃការសម្ភាស តំបន់ភូមិសាស្ត្រដែលត្រូវជ្រើសរើស
ដើម្បីឱ្យអ្នកស្រាវជ្រាវអាចជួបជាមួយអ្នកចូលរួមនៅក្នុងពេលវេលាសមស្រប ផ្អែកលើចម្ងាយពីកម្មករម្នាក់ទៅម្នាក់ និងចម្ងាយរវាងលំនៅស្ថាន របស់កម្មករ
និងលំនៅស្ថានរបស់អ្នកស្រាវជ្រាវ។
- **ភាពជាតំណាង៖** តំណាងដែលត្រូវការដើម្បីឱ្យបានជាតំណាងឱ្យក្រុមគោលដៅដែលពាក់ព័ន្ធដោយទូលំទូលាយ ប៉ុន្តែមិនមែនផ្អែកស្ថិតិ
- **ស្ថិរភាព៖** ការសិក្សាដែលជោគជ័យតម្រូវឱ្យ MFO មានសំណាកដែលស្ថិរភាពមួយសម្រាប់រយៈពេលមួយឆ្នាំ។ កិច្ចការនេះតម្រូវឱ្យក្រុមស្រាវជ្រាវចុះឈ្មោះអ្នកចូលរួម ដែលមិនទំនងជាធ្វើចំណាកស្រុកចេញ ក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះ។

អិម.អេហ្វ.អូ ពាក់ព័ន្ធនឹងនីតិវិធីជ្រើសរើសសំណាកដែលមានប្រាំជំហាន
ដោយពិចារណាពីអាទិភាពទាំងនេះ។

GARMENT WORKER DIARIES

## នីតិវិធីជ្រើសរើសសំណាកលម្អិត

**ជំហានទី១៖ ការសិក្សាស្រាវជ្រាវបឋមនិងទីពីរទៅលើទីកន្លែង និងទំនោររបស់កម្មករកាត់ដេរ**

ក្រុមស្រាវជ្រាវត្រូវបានស្នើសុំឱ្យធ្វើការស្រាវជ្រាវបឋមនិងទីពីរ ដែលខេត្ត ឬស្រុកណាខ្លះនៅក្នុងប្រទេសរបស់ពួកគេដែលមានរោងចក្រកាត់ដេរប្រមូលផ្តុំច្រើនជាងគេ។
នៅក្នុងតំបន់ទាំងនេះ អិម.អេហ្វ.អូ បានស្នើសុំឱ្យអ្នកស្រាវជ្រាវប្រមូលព័ត៌មានជាមូលដ្ឋានអំពីកម្មករកាត់ដេរដែលអាចជួយដល់យុទ្ធសាស្ត្រជ្រើសរើសសំណាក។
ក្រុមស្រាវជ្រាវបានប្រមូលព័ត៌មាននានាដូចជា កាលវិភាគការងារ និងឆន្ទៈក្នុងការធ្វើសម្ភាសន៍នៅនៅតាមរោងចក្រ ឬជិតរោងចក្រ ចម្ងាយពីផ្ទះរបស់អ្នកឆ្លើយនឹងសម្ភាសន៍ទៅរោងចក្ររាប់បញ្ចូលទាំងថាតើកម្មកររស់នៅក្នុងអន្តេវាសិកដ្ឋានរបស់រោងចក្រ និងភវនីយភាពដែលកម្មករអាចធ្វើចំណាកស្រុក។

GARMENT WORKER DIARIES

## នីតិវិធីជ្រើសរើសសំណាកលម្អិត

**ជំហានទី២៖ ជ្រើសរើសយកតំបន់រដ្ឋបាលធំ និងតូច តាមគោលបំណងដែលចង់បាន**

អង្គការ អិម.អេហ្វ.អូ បានជ្រើសរើសយកជាសំណាកនូវ តំបន់រដ្ឋបាលធំៗដែលមានការប្រមូលផ្តុំរោងចក្រកាត់ដេរច្រើននៅក្នុងប្រទេសនីមួយៗ។

ជាទូទៅតំបន់រដ្ឋបាលធំៗទាំងនេះ គឺជាទីក្រុងធំៗ ស្រុក ឬខេត្តធំៗ។ នៅក្នុងតំបន់រដ្ឋបាលធំៗទាំងនេះ អង្គការ អិម.អេហ្វ.អូ បានជ្រើសរើសុកតាមគោលបំណងដែលចង់បាននូវតំបន់រដ្ឋបាលតូចៗដែលមាន រោងចក្រកាត់ដេរ ឬផ្ទះកម្មកាត់ដេរច្រើនជាងគេ។

GARMENT WORKER DIARIES

## នីតិវិធីជ្រើសរើសសំណាកលម្អិត

**ជំហានទី ៣៖**

**ជ្រើសរើសតំបន់សម្រាប់អ្នកចុះសម្ភាសន៍ដោយចៃដន្យនៅក្នុងតំបន់រដ្ឋបាលតូចៗ**

ក្រុមស្រាវជ្រាវបានបង្កើតបញ្ជីនៃតំបន់ចុះសម្ភាសន៍ទាំងអស់ ដែលជាតំបន់ស្ទង់ងារដែលត្រូវបានប្រើសម្រាប់ជំរឿនថ្នាក់ជាតិ - ក្នុងតំបន់រដ្ឋបាលតូចនីមួយៗ។ អិម.អេហ្វ.អូ បានជ្រើសរើសកន្លែងជ្រើសរើសដោយចៃដន្យនូវតំបន់សម្រាប់ចុះសម្ភាសន៍ ដែលក្រុមស្រាវជ្រាវនឹងធ្វើការចុះឈ្មោះអ្នកឆ្លើយនឹងសម្ភាសន៍។

GARMENT WORKER DIARIES

# នីតិវិធីជ្រើសរើសសំណាកលម្អិត

**ជំហានទី ៤៖ ការកំណត់អត្តសញ្ញាណអ្នកចូលរួមដោយចៃដន្យ តាមរយៈការដើរឆ្លងកាត់ដោយចៃដន្យ**

នៅក្នុងតំបន់ចុះសម្ភាសន៍នីមួយៗ ក្រុមស្រាវជ្រាវបានធ្វើការដើរឆ្លងកាត់ដោយចៃដន្យ ដើម្បីកំណត់អត្តសញ្ញាណអ្នកឆ្លើយនឹងសម្ភាសន៍។ ការដើរឆ្លងកាត់ដោយចៃដន្យពាក់ព័ន្ធនឹងការជ្រើសរើសយកទីតាំងចាប់ផ្តើមដោយចៃដន្យ នៅក្នុងតំបន់អ្នកចុះសម្ភាសន៍ ហើយបន្ទាប់មក ចាប់ផ្តើមដើរដោយធ្វើដំណើរតាមទិសដែលបានកំណត់ដោយចៃដន្យ។ បន្ទាប់មក អ្នកចុះសម្ភាសន៍ជ្រើសរើសយកផ្ទះតាមបណ្តោយផ្លូវដែលពួកគេដើរ ដើម្បីកំណត់អត្តសញ្ញាណអ្នកចូលរួម ដោយប្រើវិធីរំលងមួយ។ និយាយម្យ៉ាងទៀត ពួកគេមិនចូលទៅគ្រប់ផ្ទះនោះទេ ពួកគេរំលងផ្ទះមួយចំនួនដែលបានកំណត់នៅមុនពេលចូលទៅលេងផ្ទះថ្មីទៀត។ ការរួមបញ្ចូលគ្នានូវការដើរចៃដន្យ និងការរំលងជួយកាត់បន្ថយភាពលម្អៀងនៅក្នុងការកំណត់អត្តសញ្ញាណអ្នកចូលរួមដែលមានសក្តានុពល។

GARMENT WORKER DIARIES

# នីតិវិធីជ្រើសរើសសំណាកលម្អិត

**ជំហានទី៥៖ ការជ្រើសរើស និងពិនិត្យសម្រាំងអ្នកចូលរួម**

អ្នកចុះសម្ភាសន៍ ចាប់ផ្តើមដំណើរការចុះឈ្មោះដោយកំណត់ពីចំនួនកម្មករកាត់ដេរដែលរស់នៅក្នុងខ្នងផ្ទះនីមួយៗ។ អ្នកចុះសម្ភាសន៍ប្រើប្រាស់ក្រឡាចត្រង្គឃីសមួយ ដើម្បីជ្រើសរើសដោយចៃដន្យកម្មករកាត់ដេរភេទស្រីម្នាក់ដែលកំពុងរស់នៅក្នុងគ្រួសារមួយ ប្រសិនបើមានច្រើនជាងម្នាក់។ ប្រសិនបើមានកម្មការនីកាត់ដេរតែម្នាក់គត់រស់នៅក្នុងផ្ទះ អ្នកចុះសម្ភាសន៍ជ្រើសរើសយកកម្មករនោះតែម្តង សម្រាប់ដំណើរការពិនិត្យសម្រាំង។

GARMENT WORKER DIARIES

## ដំណើរការពិនិត្យសម្រាំង

ដើម្បីបង្កើតសំណាកគំរូដែលមានស្ថេរភាពមួយ អិម.អេហ្វ.អូ ប្រើលក្ខណវិនិច្ឆ័យដូចខាងក្រោមដើម្បីពិនិត្យមើលកម្មករមុនពេលទទួលយកឱ្យចូលរួមនៅក្នុងកម្មវិធីនេះ៖

- *ស្ថានភាពធ្វើការពេញម៉ោង ឬក្រៅម៉ោង៖*
  មានតែអ្នកដែលធ្វើការពេញម៉ោងប៉ុណ្ណោះត្រូវបានជ្រើសរើសយក
- *កាលវិភាគរបស់កម្មករ៖* ដើម្បីធានាថាកម្មករមានវត្តមានសម្រាប់ការសម្ភាសន៍
- *បំណងដើម្បីផ្លាស់ប្តូរការងារ ឬធ្វើដំណើរ៖* អិម.អេហ្វ.អូ ដកចេញ បុគ្គលដែល រាយការណ៍ថាពួកគេមានគម្រោងផ្លាស់ប្តូររោងចក្រ ឬ បានធ្វើចំណាកស្រុកអស់រយៈពេលជាងមួយខែនៅក្នុងឆ្នាំនោះព្រោះថា បុគ្គលទាំងនេះមានហានិភ័យខ្ពស់ក្នុងការបោះបង់ចោលការសិក្សានេះ។
- *ការមានទូរស័ព្ទចល័តជាកម្មសិទ្ធិ/លទ្ធភាពទទួលបានទូរស័ព្ទចល័ត៖* ការមានទូរស័ព្ទចល័ត ឬការមានលទ្ធភាពទទួលបានទូរស័ព្ទចល័តគឺជាការចាំបាច់ដើម្បីទាក់ទងអ្នកឆ្លើយនឹងសម្ភាសន៍ ដើម្បីរៀបចំការសម្ភាសន៍ និងធ្វើសម្ភាសន៍បំពេញបន្ថែម ប្រសិនបើចាំបាច់។

GARMENT WORKER DIARIES

## ពណ៌នាសំណាក

សំណាកកម្មកររោងចក្រកាត់ដេរកម្ពុជាមានស្ត្រី ១៨៦ នាក់ មកពីរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ។ ពីរភាគបីនៃសំណាកគំរូនេះ រស់នៅក្នុង និងជុំវិញទីក្រុងភ្នំពេញ រីឯមួយភាគបីដែលនៅសល់ រស់នៅក្នុងខេត្តកំពង់ស្ពឺ។ អ្នកចូលរួមភាគច្រើន គឺស្ត្រីវ័យក្មេងដែលមានអាយុជាមធ្យម ២៩ ឆ្នាំ ហើយភាគច្រើន បានរៀបការ ហើយមានការអប់រំក្នុងប្រព័ន្ធតិចតួច។

ជាផ្នែកមួយនៃការវិភាគរបស់ អិម.អេហ្វ.អូ កម្មករត្រូវបានបែងចែកទៅតាមស្ថានភាពរស់នៅរបស់ពួកគេ និងថាតើពួកគេនៅតែជាកម្មកររោងចក្រកាត់ដេរពេញម៉ោងឬអត់នៅក្នុងអំឡុងពេលនៃការសិក្សានេះ។ ខណៈដែលផ្នែកនេះបង្ហាញទិន្នន័យអំពីកម្មករទាំងអស់ ជំពូកខាងមុខផ្តោតលើតែ ៨៥% ប៉ុណ្ណោះ នៃកម្មករដែលធ្វើការពេញម៉ោងនៅក្នុងការសិក្សាទាំងមូល។

ទិន្នន័យប្រជាសាស្ត្រ | ទិន្នន័យបែងចែកកម្មករ

GARMENT WORKER DIARIES

## ទីតាំង

ក្នុងចំណោមស្ត្រី ១៨៦ នាក់ ដែលបាន ចូលរួមក្នុងការសិក្សានេះ ប្រហែល ៦៦ ភាគរយ រស់នៅក្នុងរាជធានីភ្នំពេញ ហើយ ៣ ភាគរយរស់នៅក្នុងខេត្តកំពង់ស្ពឺ។ របាយនេះ ត្រូវបានកំណត់ដោយ អិម.អេហ្វ.អូ ដើម្បីផ្តល់ទិន្នន័យគ្រប់គ្រាន់ សម្រាប់ ធ្វើការសន្និដ្ឋានអំពីបទពិសោធន៍របស់កម្មករនៅរាជធានីភ្នំពេញ និងនៅតំបន់ជនបទនានា ដូចជា ខេត្តកំពង់ស្ពឺ។




GARMENT WORKER DIARIES

## អាយុ

អិម.អេហ្វ.អូ
បានដកចេញកម្មករដែលមានអាយុ
ក្រោម ១៨ឆ្នាំ ពីការសិក្សានេះ ប៉ុន្តែ
ប៊ែរភាគរយនៃកម្មករ និយាយថា
ពួកគេនឹងបុគ្គលដែលមានអាយុ
ក្រោម ១៨ឆ្នាំ
ដែលធ្វើការជួងមាងចក្រកាត់ដេរ។




GARMENT WORKER DIARIES
ស្ថានភាពអាពាហ៍ពិពាហ៍
៣%
៣៤%
៥៨%
៥%
នៅលីវ (មិនដែលបានរៀបការ)
បែកគ្នា
រៀបការ
មេម៉ាយ/ពោះម៉ាយ


GARMENT WORKER DIARIES
ការអប់រំដែលបានទទួល
គ្មាន និងមិនចេះអក្សរ
គ្មាន ប៉ុន្តែចេះអក្សរ
មានការអប់រំបឋមសិក្សាខ្លះ
បញ្ចប់បឋមសិក្សា
មានមធ្យមសិក្សាខ្លះ
បញ្ចប់មធ្យមសិក្សា
មធ្យមសិក្សាខ្លះ ឬខ្ពស់ជាងនេះ
បញ្ចប់មធ្យមសិក្សា ឬខ្ពស់ជាងនេះ
០% ១០% ២០% ៣០% ៤០%
ចំណែកកម្មករ







©Microfinance Opportunities. February 13, 2018.

GARMENT WORKER DIARIES

## ទំហំគ្រួសារជាមធ្យម

ទំហំគ្រួសារជាមធ្យមសម្រាប់អ្នកចូលរួមទាំងអស់គឺ ៤,៥ នាក់ក្នុងមួយគ្រួសារ។ កម្មករដែលរស់នៅជាមួយគ្រួសាររបស់ពួកគេនៅក្នុងផ្ទះផ្ទាល់ខ្លួន មានទំហំគ្រួសារធំជាងអ្នកដែលជួលផ្ទះគេ។ ទំហំខ្នងផ្ទះសម្រាប់ក្រុមនៅម្នាក់ឯង និងជួលផ្ទះគេ ឆ្លុះបញ្ចាំងពីចំនួនសមាជិកដែលកម្មកររស់នៅជាមួយ។




GARMENT WORKER DIARIES

## ស្ថានភាពរបស់កម្មករ

នៅក្នុងអំឡុងធ្វើការសិក្សានេះ កម្មករបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់យើង អំពីស្ថានភាពការងាររបស់ពួកគេនៅក្នុងរោងចក្ររបស់ពួកគេ។ តួលេខបង្ហាញពីចំនួនកម្មករដែលឈប់ពីរោងចក្រហើយមិនត្រឡប់មកវិញ អ្នកដែលឈប់សម្រាករយៈពេលយូរ ឬអ្នកដែលធ្វើការពេញម៉ោង។






[រោងចក្រកាន់តែប្រសើរនៅកម្ពុជា]




GARMENT WORKER DIARIES
ប្រភេទលំនៅស្ថានរបស់កម្មករ
កំពង់ស្ពឺ
ភ្នំពេញ
ផ្ទះដាច់ដោយឡែកពីគេ - ១០០%
ផ្ទះជួល ឬផ្ទះល្វែង - ៨០%
នៅក្នុងរាជធានីភ្នំពេញ ប្រភេទ "ផ្សេងទៀត" រួមបញ្ចូលទាំងផ្ទះដែលមានគ្រោងឆ្អឹងស្រដៀងគ្នានឹងផ្ទះល្វែង។
ផ្ទះដាច់ដោយឡែកពីគេ - ១២%
ផ្សេងទៀត - ៨%


GARMENT WORKER DIARIES
សម្ភារដែលប្រើសម្រាប់ធ្វើជញ្ជាំងរបស់ផ្ទះកម្មករ
កំពង់ស្ពឺ
ភ្នំពេញ
៨០%
៦០%
៤០%
២០%
0%







©Microfinance Opportunities. February 13, 2018.


GARMENT WORKER DIARIES
ប្រភពទឹកចម្បងរបស់កម្មករ
កំពង់ស្ពឺ
ភ្នំពេញ
១៨%
៤៣,៥%
៩,៥%
១៨%
១១%
៩៩%
ផ្គត់ផ្គង់ដោយរថយន្តដឹកទឹក
អណ្តូង/ទុយោទឹកសហគមន៍
ដងពីស្ទឹង/ទន្លេ
អណ្តូងឯកជន/ទុយោទឹក
ទឹកម៉ាស៊ីន/រ៉ូប៊ីនេក្នុងផ្ទះ


GARMENT WORKER DIARIES
មូលដ្ឋានទ្រព្យសម្បត្តិ
នៅពេលចាប់ផ្តើមការសិក្សានេះ យើងបាន
ផ្តល់ឱ្យអ្នកចូលរួមនូវបញ្ជីទ្រព្យសម្បត្តិ និង
សួរពួកគេថាតើ
មានជាតុសម្ភារណាខ្លះដែលពួកគេមាន។
អ្នកចូលរួមភាគច្រើនបានរាយការណ៍ថា
មានទ្រព្យសម្បត្តិរូបវ័ន្តតិចតួច។
វត្ថុកម្មសិទ្ធិដែលមានជាទូទៅបំផុត
គឺកៅអី។ សម្ភារទីពីរ គឺកង្ហារ។
មូលហេតុនៃការមានជាកម្មសិទ្ធិនូវទ្រព្យ
សម្បត្តិតិចតួច
ត្រូវបានស្វែងយល់នៅក្នុងជំពូកទី៤៖
ការដោះស្រាយបញ្ហាត្រូវការថ្នែកហិរញ្ញវត្ថុ។
កៅអី
កង្ហារ
ចង្ក្រាន
ចង្ក្រានហ្គាស
ទូរទស្សន៍
ម៉ូតូ/ម៉ូតូឌុប
កង់
ម៉ាស៊ីនចាក់ឌីវីឌី
វិទ្យុ
រថយន្ត
ទូទឹកកក
យានយន្ត
០
០,៤
០,៨
១,២
១,៦
ចំនួនសម្ភារជាមធ្យមដែលមានក្នុងអ្នកឆ្លើយតបការស
ម្ភាសម្នាក់

GARMENT WORKER DIARIES

## មូលដ្ឋានទ្រព្យសម្បត្តិ




GARMENT WORKER DIARIES

## លក្ខខណ្ឌរស់នៅ



GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



ខាងក្រៅផ្ទះល្វែងរបស់កម្មករក្នុងរាជធានីភ្នំពេញ

GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



ខាងក្នុងផ្ទះរបស់កម្មករក្នុងរាជធានីភ្នំពេញ

GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ




GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



ខាងក្រៅផ្ទះល្វែងរបស់កម្មករក្នុងរាជធានីភ្នំពេញ

GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



ផ្ទះបាយរបស់កម្មករ និងកន្លែងរក្សាទុកសម្ភារក្នុងរាជធានីភ្នំពេញ

GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ




GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



ឆ្នាំងនិងខ្ទះព្យួរក្នុងផ្ទះរបស់កម្មករ
ក្នុងខេត្តកំពង់ស្ពឺ

GARMENT WORKER DIARIES

## លក្ខខណ្ឌនៃការរស់នៅ



កន្លែងចម្អិនម្ហូបរបស់កម្ម
ករក្នុងខេត្តកំពង់ស្ពឺ

©Microfinance Opportunities. February 13, 2018.


GARMENT WORKER DIARIES
លក្ខខណ្ឌនៃការរស់នៅ
ខាងក្រៅផ្ទះរបស់កម្មករក្ន
ងខេត្តខេត្តកំពង់ស្ពឺ


GARMENT WORKER DIARIES
លក្ខខណ្ឌនៃការរស់នៅ
ខាងក្រៅផ្ទះរបស់កម្មករក្ន
ងខេត្តខេត្តកំពង់ស្ពឺ

GARMENT WORKER DIARIES

# ចុងបញ្ចប់នៃសង្ខេបរបស់ជំពូក

អិម.អេហ្វ.អូ បានជ្រើសរើសយកសំណាកគំរូសម្រាប់ការសិក្សាអំពីកំណត់ត្រាប្រចាំថ្ងៃរបស់កម្មករសំលៀកបំពាក់ ដើម្បីសង្កត់ធ្ងន់លើស្ថិរភាពនៅក្នុងអំឡុងឆ្នាំនៃការសិក្សានេះ។ ជាមធ្យមស្ត្រីទាំងនេះមានអាយុជិត ៣០ ឆ្នាំ ហើយភាគច្រើនរៀបការរួចហើយ។ ស្ត្រីភាគច្រើនរស់នៅជាមួយគ្រួសាររបស់ពួកគេភាគ ហើយច្រើនបំផុតរស់នៅក្នុងបន្ទប់ជួល។ រូបថតរបស់ អិម.អេហ្វ.អូ បានផ្តល់ឱ្យឃើញជារូបភាពផ្ទាល់នៃរបៀបរបបនៃការរស់នៅរបស់ស្ត្រីទាំងនេះនៅភ្នំពេញនិងកំពង់ស្ពឺ។

ក្នុងចំណោមស្ត្រី ១៨៦ នាក់ ដែលបានផ្តល់ទិន្នន័យឱ្យបានគ្រប់គ្រាន់ដើម្បីដាក់បញ្ចូលក្នុងការវិភាគ។ ៨៥% ធ្វើការពេញម៉ោងនៅក្នុងរោងចក្ររបស់ពួកគេក្នុងអំឡុងពេលនៃការសិក្សា។ ១១% បានឈប់ពីការងារ ហើយ ៤% ទៀតបានឈប់សម្រាករយៈពេលយូរ។

ផ្នែកផ្សេងទៀតនៃរបាយការណ៍ ពិនិត្យមើលបទពិសោធន៍របស់កម្មករពេញម៉ោង ដោយពិនិត្យមើលទំនាក់ទំនងរវាងប្រាក់ចំណូល ការចំណាយ និងភាពតានតឹងផ្នែកផ្នែកហិរញ្ញវត្ថុ។

GARMENT WORKER DIARIES

## ជំពូកទី២៖ ប្រាក់ឈ្នួល

អ្នកចូលរួមក្នុងការសិក្សានេះ ធ្វើការជាមធ្យម ៤៨ម៉ោង ក្នុងមួយសប្តាហ៍ ហើយពួកគេធ្វើការម៉ោងបន្ថែមចំនួន ៤៥%នៃសប្តាហ៍។ ម៉ោងបន្ថែមគឺជាផ្នែកមួយយ៉ាងសំខាន់របស់កម្មករដើម្បីបង្កើនប្រាក់ឈ្នួលរបស់ពួកគេ ដែលក្នុងនោះ ១០% នៃប្រាក់ឈ្នួលសរុបគឺបានមកពីម៉ោងបន្ថែម។ បន្ថែមពីលើនេះ ក្នុងអត្រាប្រមាណ ៣៥០០រៀលក្នុងមួយម៉ោង កម្មករភាគច្រើនរកប្រាក់ចំណូលបានប្រមាណ ៣៥០០រៀលក្នុងមួយម៉ោង កម្មករភាគច្រើនបំផុតរកចំណូលបានលើសប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៦ និង ២០១៧ គិតតាមម៉ោង។




GARMENT WORKER DIARIES

## ប្រាក់ឈ្នួលចុងក្រោយបន្ទាប់ពី ផាត់ចំណាយ

ជាមធ្យម អ្នកចូលរួមក្នុងការសិក្សានេះ ធ្វើការ ៤៨ម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែចំនួនម៉ោងនេះក៏ប្រែប្រួលទៅតាមថ្ងៃបុណ្យផងដែរ។ ជារឿយៗ ពួកគេក៏ធ្វើការម៉ោងបន្ថែមផងដែរ ដែលមានប្រមាណ ៤០%នៃសប្តាហ៍នៅក្នុងអំឡុងពេលនៃការសិក្សានេះ។

ប្រាក់ឈ្នួលសរុបដែលអ្នកចូលរួមក្នុងការសិក្សាទទួលបាន រួមមាន ប្រាក់ឈ្នួល បូកនឹងប្រាក់បន្ថែមផ្សេងទៀត ដូចជាប្រាក់ឧបត្ថម្ភ ឬប្រាក់រង្វាន់។ ទិន្នន័យបង្ហាញថា កម្មករខ្លះបានទទួលប្រាក់ឧបត្ថម្ភបន្ថែមទាំងនេះ។ ជាមធ្យម ជារួម ប្រាក់ទាំងនេះមានចំនួនសុរបប្រមាណ ១៨៥.០០០ រៀល ក្នុងមួយសប្តាហ៍ ស្មើនឹងប្រមាណ ៤៥ដុល្លារក្នុងមួយសប្តាហ៍។

ខណៈដែលប្រាក់ចំណូលរបស់កម្មករភាគច្រើន បានមកពីម៉ោងធ្វើការធម្មតាក្តី ម៉ោងបន្ថែមក៏សំខាន់ណាស់ដែរសម្រាប់ប្រាក់ចំណូលរបស់កម្មករ៖ 10%នៃប្រាក់ឈ្នួលសរុប គឺបានមកពីម៉ោងបន្ថែម។ អ្នកចូលរួមក្នុងការសិក្សាភាគច្រើនបានទទួលប្រាក់ឈ្នួលរបស់ពួកគេពេញ និងទាន់ពេលវេលា ប៉ុន្តែជាទូទៅវាមានភាពខុសគ្នារវាងកម្មករម្នាក់ៗ ទាក់ទងទៅនឹងពេលវេលាដែលពួកគេទទួលបានប្រាក់ឈ្នួល ចំនួនប្រាក់ឈ្នួលដែលពួកគេទទួលបាន ចំពោះចំនួនប្រាក់ឈ្នួលសរុប និងប្រាក់តាមម៉ោង។

ចំនួនម៉ោងដែលបានធ្វើការ

ប្រាក់ឈ្នួលចុងក្រោយបន្ទាប់ពី ផាត់ចំណាយ

GARMENT WORKER DIARIES

## សមាសភាពនៃប្រាក់ឈ្នួល

ប្រាក់ឈ្នួលចុងក្រោយបន្ទាប់ពីផាត់ចំណាយរបស់កម្មករភាគច្រើនបានមកពីប្រាក់ខែ រីឯប្រាក់ចំណូលមួយចំនួនតូចបានមកពីប្រាក់ឧបត្ថម្ភដើម្បីទិញអាហារ ឬសម្រាប់ការធ្វើដំណើរការ មិនមែនកម្មករទាំងអស់សុទ្ធតែទទួលបានប្រាក់ឧបត្ថម្ភនោះទេ។




GARMENT WORKER DIARIES

## ពេលវេលានៃការបើកប្រាក់ និងចំនួនប្រាក់ខែ

ក្រាបនេះបង្ហាញពីចំនួនប្រាក់ខែដែលបង់ទៅឱ្យអ្នកចូលរួមនៅក្នុងសប្តាហ៍ណាមួយ (ខ្សែសង្វាក់) (the line) និងទំហំជាមធ្យមនៃប្រាក់បើកប្រាក់ខែទាំងនោះ (បង្គោល the bars)។ កម្មករភាគច្រើនត្រូវបានផ្តល់ប្រាក់ខែទាន់ពេល និងពេញ ដូចជានៅក្នុងសប្តាហ៍ទី២៤ នៅពេលកម្មករ ១៦២ នាក់បានទទួលប្រាក់ជាមធ្យមចំនួន ៦៩៥,000 រៀល ($១៧០)។

ពេលផ្សេងទៀត កម្មករត្រូវបានគេបើកប្រាក់ឱ្យយឺត មួយផ្នែក ឬបានស្នើសុំបើកមុន មានន័យថា បើកប្រាក់តិចឆងជាងមុនសម្រាប់ចំនួនតិចជាងមុន។ រយៈពេលពីសប្តាហ៍ទី១២ និង ១៥- ដែលត្រូវគ្នានឹងថ្ងៃឈប់សម្រាកធំ ...គឺជាឧទាហរណ៍បែបនេះមួយ។



GARMENT WORKER DIARIES

## ពេលវេលានៃការបើកប្រាក់ និងចំនួនប្រាក់ខែ




GARMENT WORKER DIARIES

## ចំណែកនៃប្រាក់ខែពីម៉ោងបន្ថែម

ម៉ោងបន្ថែមមានសារៈសំខាន់ចំពោះប្រាក់ខែសរុបដែលកម្មកររកបាន។ ជាមធ្យម ១០ភាគរយនៃប្រាក់ឈ្នួលរបស់កម្មករ បានមកពីម៉ោងបន្ថែម។


GARMENT WORKER DIARIES
ចំនួនម៉ោងជាមធ្យម
ដែលបានធ្វើការ
ជាទូទៅ អ្នកចូលរួមក្នុងការសិក្សានេះ
ធ្វើការជាមធ្យម ៤៨ម៉ោង ក្នុងមួយសប្តាហ៍
មួយ ទោះបីជា
មានបម្រែបម្រួលខ្លះរវាងស្ថានភាពរស់នៅ
ផ្សេងៗ។
៤៨ម៉ោងក្នុងមួយសប្តាហ៍
គឺចំនួនអតិបរមាដែល
បានអនុញ្ញាតនៅក្នុងច្បាប់ការងារកម្ពុជា
មុនពេលកម្មករមានសិទ្ធិទទួលបានប្រាក់
ម៉ោងបន្ថែម។
រោងចក្រកាន់តែប្រសើរនៅកម្ពុជា
ចំនួនម៉ោងជាមធ្យម
៥០
៤០
៣០
២០
១០
០
តែម្នាក់ឯង & ជួល
គ្រួសារ & និងកម្មសិទ្ធិផ្ទាល់ខ្លួន
គ្រួសារ & ជួល


GARMENT WORKER DIARIES
ចំនួនម៉ោងជាមធ្យម ដែលបានធ្វើការ
ចំនួនម៉ោងជាមធ្យម
៥០
៤០
៣០
២០
១០
០
រោងចក្រក្រោមកម្មវិធី 'រោងចក្រកាន់តែប្រសើរនៅកម្ពុជា'
រោងចក្រផ្សេងទៀត

GARMENT WORKER DIARIES

## បម្រែបម្រួលម៉ោងធ្វើការ

ទោះបីកម្មករធ្វើការជាមធ្យម ៤៨ម៉ោង ក្នុងមួយសប្តាហ៍ក្តី ចំនួននេះមិនបានបង្ហាញពីភាពងាយ ប្រែប្រួលនៃម៉ោងធ្វើការរបស់ពួកគេ។

ដូចដែលក្រាហ្វិកបានបង្ហាញ អ្នកចូលរួមក្នុងការ សិក្សាមានការកាត់បន្ថយធំៗនៅក្នុង ម៉ោងធ្វើការគិតជាសប្តាហ៍ ដោយមានថ្ងៃឈប់សម្រាកធំៗ ដែលកាត់បន្ថយមធ្យមភាគ។

នៅក្នុងសប្តាហ៍ដែលគ្មានថ្ងៃបុណ្យឈប់ស ម្រាក *ជារឿយៗកម្មករធ្វើការច្រើនជាង ៥០ ម៉ោងក្នុងមួយសប្តាហ៍។*




GARMENT WORKER DIARIES

## ភាពងាយប្រែប្រួលនៃម៉ោងធ្វើការ



GARMENT WORKER DIARIES

## ម៉ោងបន្ថែម

ក្នុងសប្តាហ៍ភាគច្រើន អ្នកចូលរួមក្នុងការសិក្សាធ្វើការ ៤៨ម៉ោងឬតិចជាងនេះ ដោយរាប់ទាំងសប្តាហ៍ដែលមានចំនួនម៉ោងធ្លាក់ចុះ ដោយសារថ្ងៃបុណ្យឈប់សម្រាក ជំងឺ ឬពេលឈប់ផ្សេងទៀត។

នៅក្នុងប្រហែល ៤០ភាគរយនៃសប្តាហ៍ កម្មករធ្វើការពី ៤៨ម៉ោង ដល់ ៦០ម៉ោងក្នុងមួយសប្តាហ៍។ ទាំងនេះគឺជាម៉ោងបន្ថែមតាមច្បាប់ – ច្បាប់ការងារកម្រិតម៉ោងបន្ថែមតាមច្បាប់ត្រឹម ៦០ម៉ោងក្នុងមួយសប្តាហ៍។

នៅក្នុងប្រហែល ៥ភាគរយនៃសប្តាហ៍ទាំងអស់ កម្មករបានប្រាប់ថា ធ្វើការលើស៦០ម៉ោងក្នុងមួយសប្តាហ៍ ដែលជាចំនួនម៉ោងបន្ថែមខុសច្បាប់។




GARMENT WORKER DIARIES

## ម៉ោងធ្វើការ និងប្រាក់ឈ្នួល

កម្មករកាត់ដេរទទួលបានប្រាក់ឈ្នួលអប្បបរមាមួយក្រោមច្បាប់ការងារកម្ពុជា។ ក្នុងឆ្នាំ២០១៦ ក្នុងអំឡុងពេល ២៧សប្តាហ៍ដំបូងនៃការសិក្សានេះ ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ត្រឹមប្រមាណ ៥៧៣.០០០ រៀល ក្នុងមួយខែ។ រដ្ឋាភិបាលបានដំឡើងប្រាក់ឈ្នួលអប្បបរមាក្នុងខែមករា ឆ្នាំ២០១៧ ដល់ប្រមាណ ៦២៦.០០០ រៀល (១៥៣ដុល្លារ) ក្នុងមួយខែ ដែលជាកំណើនចំនួន៩ភាគរយធៀបនឹងឆ្នាំមុន។

ផ្អែកលើសប្តាហ៍ធ្វើការចំនួន៤៨ម៉ោង និងខែជាមធ្យម ប្រាក់ឈ្នួលអប្បបរមាតាមច្បាប់គឺស្មើនឹងប្រមាណ ២៧៥០ រៀល (៦៧សេន) ក្នុងមួយម៉ោងក្នុងឆ្នាំ២០១៦ និង ៣.០០៤ រៀល (៧៣សេន) ក្នុងមួយម៉ោងក្នុងឆ្នាំ២០១៧។ ទិន្នន័យនេះបង្ហាញថា កម្មករភាគច្រើនបំផុតរកប្រាក់ចំណូលបានច្រើនជាងប្រាក់ឈ្នួលអប្បបរមាក្នុងអំឡុងពេលសង្កេតក្នុងឆ្នាំ២០១៦ និង ២០១៧។ អត្រាម៉ោងជាមធ្យមរបស់ពួកគេគឺ ៣.៤៩៦ រៀល (៨៥សេន)។

ទោះបីជានេះគឺជាចំណុចវិជ្ជមាន ប៉ុន្តែវាលាក់បាំងចំណុចលម្អិតនៅក្នុងការយល់ពីប្រាក់ចំណូលរបស់កម្មករ។ ដូចដែលស្លាយនេះនឹងបង្ហាញស្រាប់ កម្មករពឹងផ្អែកលើម៉ោងបន្ថែម។

ប្រាក់ឈ្នួលតាមម៉ោង

ការគណនាប្រាក់ឈ្នួល




**“ចំណុចផ្តោតសំលៀកបំពាក់៖ សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានប្រាក់ឈ្នួលសម្រាប់រស់នៅ”**




GARMENT WORKER DIARIES
ប្រាក់ឈ្នួលតាមម៉ោងមុននិងក្រោយផ្លាស់ប្តូរ
មុនពេលការប្រែប្រួលប្រាក់ឈ្នួល
បន្ទាប់ពីការប្រែប្រួលប្រាក់ឈ្នួល
៤K
៣K
២K
១K
0
រោងចក្រក្រោមកម្មវិធី 'រោងចក្រកាន់តែប្រសើរនៅកម្ពុជា'
រោងចក្រផ្សេងទៀត


GARMENT WORKER DIARIES
កម្មករដែលបានប្រាក់ឈ្នួលអប្បបរមា
មិនមែនកម្មករគ្រប់រូបបានទទួលប្រាក់ឈ្នួលអប្បរមា ឬមានទទួលអត្ថប្រយោជន៍ពីកំណើនប្រាក់ឈ្នួលនេះទេ។ ក្នុងចំណោមកម្មករធ្វើការពេញម៉ោង
៩ភាគរយរកចំណូលតាមម៉ោង
ដែលតិចជាងប្រាក់ឈ្នួលអប្បបរមាឆ្នាំ
២០១៧
ក្នុងអំឡុងពេលនៃការសិក្សានេះ។
៩%
៩១%
សប្រាក់ឈ្នួលអប្បបរមា
ក្រោមប្រាក់ឈ្នួលអប្បបរមា

GARMENT WORKER DIARIES

# ចុងបញ្ចប់នៃសង្ខេបជំពូក

អ្នកចូលរួមក្នុងការសិក្សា បានធ្វើការ ៤៨ម៉ោងក្នុងមួយសប្តាហ៍ជាមធ្យម ប៉ុន្តែមធ្យមភាគនេះត្រូវបានទាញឱ្យចុះទាបដោយសប្តាហ៍ដែលមានថ្ងៃបុណ្យ។ នៅពេលក្រឡេកមើលសប្តាហ៍ការងារជាទៀងទាត់ អ្នកចូលរួមក្នុងការសិក្សានេះធ្វើការយ៉ាងតិច ៥០ម៉ោង។ ម៉ោងបន្ថែមទាំងនេះមានសារៈសំខាន់ចំពោះកម្មករ ព្រោះថា ១០%នៃប្រាក់ចំណូលសរុបរបស់ពួកគេ គឺបានមកពីម៉ោងបន្ថែម។

គិតតាមម៉ោងនិងជារួម កម្មករបានទទួលប្រាក់ឈ្នួលលើសប្រាក់ឈ្នួលអប្បបរមាក្នុងឆ្នាំ២០១៦ និង ២០១៧។ វាជាចំណុចវិជ្ជមានដែលថា កម្មករបានទទួលលើសប្រាក់ឈ្នួលអប្បបរមា ប៉ុន្តែជំពូកបន្ទាប់នឹងបង្ហាញថា សូម្បីតែមានប្រាក់ឈ្នួលកាន់តែខ្ពស់ទាំងនេះក្តី ក៏កម្មករនៅតែមានជួបការលំបាកក្នុងការបំពេញតម្រូវការចាំបាច់របស់ខ្លួន ខណៈពេលជាមួយគ្នានោះ រៀបចំផែនការសម្រាប់គ្រោះអាសន្ន ព្រឹត្តិការណ៍ធំៗក្នុងជីវិត និងការកែលម្អទូទៅនៅក្នុងកម្រិតជីវភាពរបស់នៅរបស់ពួកគេ។



GARMENT WORKER DIARIES
ជំពូកទី ៣៖ ការចំណាយ
ក្នុងចំណោមប្រាក់ដែលចំណាយលើទំនិញ និងសេវា អ្នកចូលរួមបានចំណាយ ៨៦ ភាគរយលើទំនិញប្រើរយៈពេលខ្លី សម្ភារប្រើប្រាស់ ឬសេវាផ្សេងៗ រួមទាំង ៥៥ភាគរយ លើអាហារ។ កង្វះការចំណាយលើទំនិញសម្រាប់ប្រើយូរអង្វែង ក៏ដូចជា ទិន្នន័យផ្សេងទៀត បង្ហាញថា កម្មករជួបការលំបាកក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។
ការចំណាយក្នុងគ្រួសារ
កម្រិតជីវភាព
ការទិញសរុបរួម




GARMENT WORKER DIARIES
ការចំណាយប្រចាំខែ
ជាមធ្យម កម្មករចំណាយតិចជាងប្រាក់ដែលពួកគេរកបានក្នុងខែនីមួយៗ ប៉ុន្តែគ្រួសារដែលបង់ប្រាក់ឈ្នួលផ្ទះ ចំណាយច្រើនជាងគ្រួសារដែលមានផ្ទះខ្លួនឯងបន្តិច។
ផ្នែកនេះនឹងពិនិត្យមើលការចំណាយរបស់កម្មករ ស្វែងយល់ពីអាទិភាពនៃការចំណាយរបស់ពួកគេ ក៏ដូចជាការប្រែប្រួលនៃការចំណាយរបស់ពួកគេក្នុងសប្តាហ៍នីមួយៗ។ ជំពូកខាងក្រោមនេះ នឹងពិភាក្សាអ្វីដែលអ្នកចូលរួមក្នុងការសិក្សាធ្វើជាមួយប្រាក់ចំណូលដែលនៅសល់របស់ពួកគេ និងព្យាបាលពន្យល់ហេតុអ្វីបានជាការចំណាយរបស់ពួកគេ ទាបជាងចំណូល។
៨០០K
៦០០K
៤០០K
២០០K
0
តែម្នាក់ឯង និងថ្លៃជួលផ្ទះ
គ្រួសារ និងមានផ្ទះខ្លួនឯង
គ្រួសារ និងថ្លៃជួលផ្ទះ
ប្រាក់ចំណូលពីរោងចក្រ
ការចំណាយក្នុងគ្រួសារ

GARMENT WORKER DIARIES

# ការចំណាយប្រចាំសប្តាហ៍

ស្លាយទាំងឡាយខាងក្រោមនេះ នឹងពិនិត្យមើលការចំណាយប្រចាំសប្តាហ៍ជាមធ្យមក្នុងអំឡុងពេលនៃការសិក្សានេះ។ អឹម.អេហ្វ.អូ ធ្វើចំណាត់ថ្នាក់ការចំណាយជាក្រុមនានាដូចខាងក្រោម៖

- អាហារ៖ អាហារដែលមិនទានបានចម្អិន និងអាហារដែលបានរៀបចំរួចស្រេច
- លំនៅស្ថាន៖ ថ្លៃឈ្នួលផ្ទះ និងថ្លៃទឹកភ្លើង
- សេវាសុខភាព និងសេវាជាមូលដ្ឋានផ្សេងទៀត៖ សុខភាព អនាម័យផ្ទាល់ខ្លួន មធ្យោបាយដឹកជញ្ជូន ការអប់រំ និង ទំនាក់ទំនង/ទូរស័ព្ទ
- សម្ភារប្រើប្រាស់ក្នុងផ្ទះ និងឥន្ធនៈ ហ្គាស សាំង សម្ភារប្រើប្រាស់ក្នុងផ្ទះប្រចាំ (សម្ភារអនាម័យ សំលៀកបំពាក់ ចានឆ្នាំង ។ល។)
- កសិកម្ម និងសំណង់៖ ដី ថ្នាំកសិកម្ម សម្ភារកសិកម្មផ្សេងទៀត សម្ភារសំណង់ (ឥដ្ឋ ដីខ្សាច់ ស៊ីម៉ងត៍ ទ្វារ សម្ភារដំបូល ។ល។)
- ព្រឹត្តិការណ៍ពិសេស៖ អាពាហ៍ពិពាហ៍ ខួបកំណើត និងចូលបុណ្យផ្សេងៗ
- ផ្សេងទៀត៖ សារធាតុកម្សាន្ត អេឡិចត្រូនិក គ្រឿងសំអាង សម្ភារកម្សាន្ត ។ល។

GARMENT WORKER DIARIES

## ការចំណាយប្រចាំសប្តាហ៍ជាមធ្យម

ជាមធ្យម គ្រួសារចំណាយប្រហែល ១២០.០០០ រៀល ក្នុងមួយសប្តាហ៍ ទោះបីជាការចំណាយនេះ ប្រែប្រួលផ្អែកលើស្ថានភាពរស់នៅក្តី។

ប្រហែល ៥៥ភាគរយនៃការចំណាយលើទំនិញ និងសេវា គឺលើម្ហូបអាហារ។ ប្រហែល ១៧ ភាគរយនៃការចំណាយគឺលើលំនៅស្ថាន សម្រាប់អ្នកដែលជួលផ្ទះគេ។

ចុចលើប៊ូតុង "ចំណែក" ដើម្បីស្វែងរកភាពខុសគ្នារវាង ស្ថានភាពរស់នៅ.សូមមើលថាតើអ្នកអាច ឃើញតើម្ចាស់ផ្ទះចំណាយប្រាក់ដែលគេមិនចំណាយលើការជួលផ្ទះ ដូចម្តេច។

គន្លឹះជំនួយ៖
ជារឿយៗ អឹម.អេហ្វ.អូ បង្ហាញការចំណាយជាមធ្យមភាគ ក្នុងមួយសប្តាហ៍។ ព័ត៌មាននេះជួយប្រក្រតីនីយកម្មទិន្នន័យសម្រាប់ភាពខុសគ្នា ដោយផ្អែកលើអ្នកចូលរួមផ្សេងៗគ្នា ឬអនុចំណែកនៃសំណាកដែលបំពេញការសម្ភាសន៍មួយចំនួនផ្សេងទៀត។




GARMENT WORKER DIARIES
ការចំណាយប្រចាំសប្តាហ៍ជាមធ្យម
១៨០K
១៥០K
១២០K
៩០K
៦០K
៣០K
0


GARMENT WORKER DIARIES
តែម្នាក់ឯង និងថ្លៃជួលផ្ទះ
២០០K
១៦០K
១២០K
៨០K
៤០K
0


GARMENT WORKER DIARIES
គ្រួសារ និងមានកម្មសិទ្ធិផ្ទាល់ខ្លួន
២០០K
១៦០K
១២០K
៨០K
៤០K
0


GARMENT WORKER DIARIES
គ្រួសារ និងថ្លៃជួលផ្ទះ
២០០K
១៦០K
១២០K
៨០K
៤០K
0


GARMENT WORKER DIARIES
ចំណែក
ការចំណាយនៅមុន និងក្រោយ
កំណើនប្រាក់ឈ្នួលអប្បបរមា
ជំពូកទី២ បង្ហាញថា កម្មករបានទទួលកំណើន
តិចបំផុតនៅក្នុងប្រាក់ឈ្នួលរបស់ពួកគេ។
តើនេះមានន័យថា
ការចំណាយខ្ពស់ជាងមុនឬទេ?
បន្ទាប់ពីមានការផ្លាស់ប្តូរប្រាក់ឈ្នួលអប្បបរ
មា ការចំណាយរបស់កម្មករ
កើនឡើងបន្តិចនៅក្នុងការចំណាយគ្រប់ខ្ទង់។
សរុបមក កំណើននៅក្នុងការចំណាយនេះ
នៅគ្រប់ខ្ទង់ គឺស្មើទៅនឹងការផ្លាស់
ប្តូរប្រាក់ឈ្នួលរបស់កម្មករ។
និយាយម្យ៉ាងទៀត កម្មករចំណាយប្រាក់ឈ្នួល
បន្ថែមទៀត ដែលពួកគេបានទទួលក្រោយពី
រដ្ឋាភិបាលបានដំឡើងប្រាក់ឈ្នួលអប្បបរមា។
២០០K
១៦០K
១២០K
៨០K
៤០K
0
អាហារ
មុនពេលប្រែប្រួលប្រាក់ឈ្នួល
ក្រោយពេលប្រែប្រួលប្រាក់ឈ្នួល


GARMENT WORKER DIARIES
ការចំណាយនៅមុន និងក្រោយកំណើនប្រាក់ឈ្នួលអប្បបរមា
២០០K
១៦០K
១២០K
៨០K
៤០K
0
អាហារ
មុនពេលផ្លាស់ប្តូរប្រាក់ឈ្នួល
ក្រោយពេលផ្លាស់ប្តូរប្រាក់ឈ្នួល


GARMENT WORKER DIARIES
តែម្នាក់ឯង & ថ្លៃជួលផ្ទះ
២០០K
១៦០K
១២០K
៨០K
៤០K
0
មុនពេលផ្លាស់ប្តូរប្រាក់ឈ្នួល
ក្រោយពេលផ្លាស់ប្តូរប្រាក់ឈ្នួល


GARMENT WORKER DIARIES
គ្រួសារ និងកម្មសិទ្ធិផ្ទាល់
២០០K
១៦០K
១២០K
៨០K
៤០K
0
មុនពេលផ្លាស់ប្តូរប្រាក់ឈ្នួល
ក្រោយពេលផ្លាស់ប្តូរប្រាក់ឈ្នួល

GARMENT WORKER DIARIES

## គ្រួសារ និងថ្លៃជួលផ្សេងៗ




GARMENT WORKER DIARIES

## ការចំណាយទៅតាមពេលវេលា

បន្ថែមពីលើការយល់ពីមធ្យមភាគ
ជាការសំខាន់ដែល
ត្រូវបង្ហាញតើការចំណាយប្រែប្រួលទៅតាមពេល
វេលាដូចម្តេច។
ក្រាហ្វិកនេះបង្ហាញថា ខ្ទង់ចំណាយភាគច្រើន-
ជាពិសេស ម្ហូបអាហារ សម្ភារប្រើប្រាស់ក្នុងផ្ទះ
និងសេវាសុខភាពនិងសេវាជាមូលដ្ឋាន-មាន
លក្ខណៈថេរគួរសមពីមួយសប្តាហ៍មួយសប្តាហ៍។
មានកំណើនជាច្រើននៅក្នុងការចំណាយ
ដែលជំរុញដោយ
ការចំណាយប្រចាំខែជាទៀងទាត់ (លំនៅស្ថាន)
និង ការចំណាយផ្សេងៗតាមពេលកំណត់
លើព្រឹត្តិការណ៍ផ្សេងៗ ដូចជា អាពាហ៍ពិពាហ៍
ទោះបីជាកំណើននៃការចំណាយមានជាទូទៅ
សម្រាប់អ្នកជួលផ្ទះគេ
ច្រើនជាងអ្នកមានផ្ទះខ្លួនឯងក្តី។
សូមចុចលើប៊ូតុង "ចំណែក" ("Segments")
ដើម្បីទទួលមានព័ត៌មានបន្ថែមទៀត
អំពីថាតើក្រុមកម្មករផ្សេងៗ
ចំណាយប្រាក់ដូចម្តេច ទៅតាមពេលវេលា។




GARMENT WORKER DIARIES
ការចំណាយទៅតាមពេលវេលា
៣០០K
២០០K
១០០K
0
ចំនួនប្រាក់ចាយមធ្យម (រៀល)
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនសប្តាហ៍នៃការសិក្សា
អាហារ
លំនៅស្ថាន
សុខភាព & សេវាជាមូលដ្ឋាននានា
សម្ភារប្រើប្រាស់ក្នុងផ្ទះ & ប្រេងឥន្ធនៈ
កសិកម្ម & សំណង់
ព្រឹត្តិការណ៍ពិសេស


GARMENT WORKER DIARIES
តែម្នាក់ឯង និងថ្លៃជួលផ្ទះ
៤០០K
៣០០K
២០០K
១០០K
0
ចំនួនប្រាក់ចាយមធ្យម (រៀល)
ការកើនឡើងនៃការចំណាយលើសេវាសុខ
ភាពនិងសេវាចាំបាច់ផ្សេងទៀតតាមធម្មតា
ត្រូវបានជំរុញដោយការបង់ប្រាក់ដ៏ច្រើន
តែមួយដងរបស់កម្មករសម្រាប់ជួលគោរី
គុ និងគង់សម្រាប់ពិធីរៀបការរបស់នាង។
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនសប្តាហ៍នៃការសិក្សា
អាហារ
លំនៅដ្ឋាន
សុខភាព & សេវាជាមូលដ្ឋាននានា
សម្ភារប្រើប្រាស់ក្នុងគ្រួសារ & ប្រេងឥន្ធនៈ
កសិកម្ម & សំណង់
ព្រឹត្តិការណ៍ពិសេស



GARMENT WORKER DIARIES
គ្រួសារ និងមានកម្មសិទ្ធិ
៤០០K
៣០០K
២០០K
១០០K
0
ចំនួនប្រាក់សរុបជាមធ្យម (រៀល)
ការកើនឡើងនៃការចំណាយ
ជាមធ្យមនេះ
ត្រូវបានជំរុញដោយសារ
កាដូ/ចំណងដៃយ៉ាងច្រើនស
ម្រាប់ការឡើងគេហដ្ឋានថ្មី
កំណើននៃការចំណាយជាមធ្យមទាំងពីរ
ត្រូវបានជំរុញដោយការ
ទិញសម្ភារសំណង់ដ៏ច្រើនរបស់កម្មករនៅ
ក្នុងសប្តាហ៍នីមួយៗ។
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនសប្តាហ៍នៃការសិក្សា
អាហារ
លំនៅស្ថាន
សុខភាព & សេវាជាមូលដ្ឋាននានា
សម្ភារប្រើប្រាស់ក្នុងគ្រួសារ & ប្រេងឥន្ធនៈ
កសិកម្ម & សំណង់
ព្រឹត្តិការណ៍ពិសេស




GARMENT WORKER DIARIES
គ្រួសារ និងថ្លៃជួល
៤០០K
៣០០K
២០០K
១០០K
0
ចំនួនប្រាក់សរុបជាមធ្យម (រៀល)
កំណើននៃការចំណាយជាមធ្យ
មនេះត្រូវបានជំរុញដោយការចំ
ណាយលើចំនួនដ៏ធំមួយ
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនសប្តាហ៍នៃការសិក្សា
អាហារ
លំនៅស្ថាន
សុខភាព & សេវាជាមូលដ្ឋាននានា
សម្ភារប្រើប្រាស់ក្នុងគ្រួសារ & ប្រេងឥន្ធនៈ
កសិកម្ម & សំណង់
ព្រឹត្តិការណ៍ពិសេស

GARMENT WORKER DIARIES

## ការលើកកម្ពស់ជីវភាពរស់នៅ

វិធីមួយទៀតដើម្បីធ្វើចំណាត់ថ្នាក់ការចំណាយលើទំនិញនិងសេវាកម្ម គឺត្រូវគិតពីថាតើការទិញគឺសម្រាប់ប្រើប្រាស់ភ្លាមៗ ឬថាតើវាជាការវិនិយោគមួយនៅក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់បុគ្គល។ ទំនិញនិងសេវាកម្មសម្រាប់ការប្រើប្រាស់ភ្លាមៗ គឺមិនមានអាយុកាលយូរអង្វែងទេ។ ទោះបីជាវាសំខាន់សម្រាប់ការរស់នៅប្រចាំថ្ងៃ ជាទូទៅវាមិនធ្វើឱ្យមានការផ្លាស់ប្តូរធំដុំទៅលើជីវភាពរស់នៅ។ ទំនិញនិងសេវាដើម្បីលើកកម្ពស់ជីវភាពរស់នៅ អាចជា៖

- **សម្ភារកសិកម្ម៖** សម្ភារៈកសិកម្មគឺសម្រាប់ការងារកសិកម្មជាលក្ខណៈគ្រួសារ ក៏ដូចជាផលិតកម្មបង្កើតប្រាក់ចំណូល។
- **ទំនិញដែលអាចប្រើបានយូរអង្វែង៖** ទ្រព្យសម្បត្តិដែលទំនងជាមានរយៈពេលជាច្រើនឆ្នាំ ដូចជា ផ្ទាំង ខ្ទះ ឬម៉ូតូ។
- **ការវិនិយោគលើការអប់រំ៖** សម្រាប់មនុស្សពេញវ័យនិងកុមារ ការអប់រំគឺផ្សារភ្ជាប់ទៅនឹងលទ្ធផលសេដ្ឋកិច្ចកាន់តែប្រសើរ។
- **ការជួលកម្លាំងការងារ៖** ការវិនិយោគនៅក្នុងការផលិតផលិតផលមួយ ជារឿយៗត្រូវបានប្រើប្រាស់នៅក្នុងការធ្វើកសិកម្ម ដើម្បីជួយនៅក្នុងការប្រមូល ឬនៅក្នុងការសង់ផ្ទះ
- **ការថែទាំសុខភាព៖** ការលើកកម្ពស់សុខភាព គឺកែលម្អគុណភាពនៃជីវិត

GARMENT WORKER DIARIES

## ការចំណាយលើការរស់នៅ

ចំណែក

ប្រាក់ភាគច្រើនត្រូវបានចំណាយលើទំនិញ និងសេវាកម្ម ដែលមានអាយុកាលមិនយូរអង្វែង ដែលបង្ហាញថា អ្នកចូលរួមក្នុងការសិក្សា កម្រទិញទ្រព្យសម្បត្តិ ឬការទិញផ្សេងៗទៀតដែលនាំឱ្យមានភាពប្រសើរនៃជីវភាពរស់នៅក្នុង រយៈពេលមធ្យមឬវែង។




GARMENT WORKER DIARIES
ការចំណាយលើការរស់នៅ
សាច់ និងត្រី
អាហារដែលចម្អិនរួច
ថ្លៃជួលផ្ទះប្រចាំខែ
បន្លែ
សំលៀកបំពាក់
គ្រឿងទេស
អាហារថ្លៃត្រង់
LPG
ឧបករណ៍ & បរិក្ខារ
ពលកម្ម
សម្ភារកសិកម្ម
ការវិនិយោគលើការអប់រំ
ការថែទាំសុខភាព
ទំនិញដែលប្រើបានយូរអង្វែង
ការជួលកម្លាំងការងារ
ទំនិញដែលប្រើរយៈពេលខ្លី/សេវា


GARMENT WORKER DIARIES
ចំណែកនៃប្រាក់ដែលបានចំណាយ តាមខ្ទង់ និងប្រភេទ
តែម្នាក់ឯង & ថ្លៃជួលផ្ទះ
៤.៥%
២.៥%
៩៣%
គ្រួសារ & មានកម្មសិទ្ធិផ្ទាល់ខ្លួន
១២%
៣%
៣%
៨១%
គ្រួសារ & ថ្លៃជួលផ្ទះ
៦%
១%
៣%
៨៩%
សម្ភារកសិកម្ម
ការវិនិយោគលើការអប់រំ
ការថែទាំសុខភាព
ទំនិញដែលប្រើបានយូរអង្វែង
ការជួលកម្លាំងការងារ
ទំនិញដែលប្រើរយៈពេលខ្លី/សេវា

GARMENT WORKER DIARIES

# ការទិញបញ្ចូលគ្នា

ការទិញជាដុំ គឺជាការទិញដែលមានទំហំធំជាពិសេស សម្រាប់អ្នកចូលរួមក្នុងការសិក្សា។ អឹម.អេហ្វ.អូ ស្វែងរកការទិញទាំងនេះដោយពិនិត្យមើលលើការចំណាយដែលមានគម្លាតស្តង់ដារច្រើនជាងបីគងឆ្ងាយពីការទិញជាមធ្យមសម្រាប់អ្នកចូលរួមម្នាក់ៗ។ ការទិញបញ្ចូលគ្នាគឺមានសារៈសំខាន់ក្នុងការយល់អំពីជីវិតរស់នៅរបស់កម្មករដោយមូលហេតុសំខាន់ ពីរ៖

- ការទិញបញ្ចូលគ្នាត្រូវការសាច់ប្រាក់សុទ្ធ៖ ប្រសិនបើអ្នកចូលរួមក្នុងការសិក្សា មិនទិញទំនិញធំៗ ពួកគេកំពុងព្យាយាមប្រមែប្រមូលសាច់ប្រាក់ ឬកំពុងតែកាន់សាច់ប្រាក់ជំនួសវិញ។ កាលៈទេសៈនេះជាការពិត ហើយដូច្នេះហើយបានជាអាចផ្តល់នូវការយល់ដឹងពីកម្រិតផ្សេងៗនៃភាពតានតឹងផ្នែកហិរញ្ញវត្ថុ។
- ប្រភេទនៃការទិញដែលអ្នកចូលរួមក្នុងការសិក្សា ធ្វើឡើង ប្រាប់អ្នកអំពីស្ថានភាពរបស់ពួកគេ។ សម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាប ការទិញធំៗលើតម្រូវការមូលដ្ឋាន ដូចជាលំនៅស្ថាន ម្ហូបអាហារ ការថែទាំសុខភាព ឬការអប់រំ ក្រៅពីទ្រព្យសម្បត្តិ អាចបង្ហាញពីការលំបាកនៅក្នុងការលើកកម្ពស់ជីវភាពរស់នៅ។

ការទិញបញ្ចូលគ្នា

GARMENT WORKER DIARIES

# ប្រភេទនៃការទិញរួមបញ្ចូលគ្នា

អ្នកចូលរួមក្នុងការសិក្សា ធ្វើការទិញរួមបញ្ចូលគ្នាយ៉ាងញឹកញាប់។ ជាមធ្យម ពួកគេបានទិញទំនិញធំមួយរៀងរាល់ ៤១ ថ្ងៃម្តង ហើយស្ទើរតែមួយភាគបីនៃការទិញទាំងនេះគឺនៅលើថ្លៃឈ្នួលផ្ទះ/បន្ទប់ ឬ ទឹកភ្លើង។ ការទិញជាទូទៅបំផុតបន្ទាប់មកទៀត គឺទៅលើវត្ថុសំខាន់ៗដូចជា៖ ការទិញក្នុងបរិមាណច្រើននៃម្ហូបអាហារ ឬរបស់របរសម្រាប់គ្រួសារ (ជាញឹកញាប់ គឺ សម្លៀកបំពាក់) ប៉ុន្តែវាកម្រនឹងកើតឡើងជាមធ្យម លើសពីម្តងបន្តិចក្នុងមួយឆ្នាំ។

គម្រុយជំនួយ៖
០,០១ ប្រតិបត្តិការក្នុងមួយសប្តាហ៍ ស្មើនឹងមួយប្រតិបត្តិការ រៀងរាល់ពីរឆ្នាំ ០,០២ស្មើនឹងមួយដង រៀងរាល់ឆ្នាំ។




GARMENT WORKER DIARIES
ប្រភេទនៃការទិញរួមបញ្ចូលគ្នា
០.០៨
០,០៦
០,០៤
០,០២
០,០


GARMENT WORKER DIARIES
ភាពញឹកញាប់នៃ
ការទិញរួមបញ្ចូលគ្នា
ការទិញរួមបញ្ចូលគ្នា
មានភាពកាន់តែញឹកញាប់ជាង
នេះក្នុងអំឡុងសប្តាហ៍ដែល ដែលកម្មករ
បានទទួលប្រាក់ខែរបស់ពួកគេ។
ការចំណាយ
ជាច្រើនក្នុងចំណោមការចំណាយទាំងអស់គឺ
សម្រាប់ថ្លៃឈ្នួលផ្ទះ និងទឹកភ្លើង។
ដែលដល់ពេល
ត្រូវបង់ក្នុងសប្តាហ៍ដូចគ្នានឹងសប្តាហ៍បើក
ប្រាក់ខែរបស់អ្នកចូលរួមក្នុងការសិក្សាដែរ។
ទោះបីជាដោយពិចារណាអំពីការទិញផ្ទះ
ក៏ដោយក៏ក្រាហ្វនេះបង្ហាញថា
កម្មករស្ទើរតែតែងតែទិញទំនិញធំៗ
នៅពេលដែលពួកគេទទួលបានប្រាក់ខែ
ហើយមានលុយច្រើន។
១០០%
៨០%
៦០%
៤០%
២០%
០%
ចំណែកនៃសប្តាហ៍
សប្តាហ៍ដែលមិនមានបើកប្រាក់ខែ
សប្តាហ៍ដែលមានបើកប្រាក់ខែ
សប្តាហ៍ដែលមានការទិញដោយបង់ប្រាក់ដុល
សប្តាហ៍ដែលមិនមានការទិញដោយបង់ប្រាក់ដុល

GARMENT WORKER DIARIES

## ចុងបញ្ចប់នៃសង្ខេបជំពូក

ជំពូកនេះបង្ហាញពីអ្វីដែលអ្នកចូលរួមក្នុងការសិក្សា ចំណាយប្រាក់របស់ពួកគេ និងចំណាយនៅពេលណា។ វាបង្ហាញថា លំហូរចូលពីការបើកប្រាក់ខែ នាំឱ្យមានការកើនឡើងនៅក្នុងចំណាយ ប៉ុន្តែការចំណាយនេះត្រូវបានជំរុញដោយការចំណាយមួយធំៗ ដូចជា ថ្លៃឈ្នួលផ្ទះជាដើម។

ក្នុងចំណោមការចំណាយលើទំនិញនិងសេវាកម្មទាំងអស់ ជាងពាក់កណ្ដាលគឺលើម្ហូបអាហារ និងការចំណាយលើតម្រូវការចាំបាច់នានា ដូចជា ថ្លៃឈ្នួលផ្ទះ ទឹកភ្លើង និងសម្ភារប្រើប្រាស់ក្នុងគ្រួសារ ដែលជាការចំណាយភាគច្រើននៃការចំណាយរបស់អ្នកចូលរួមក្នុងការសិក្សានេះ នៅក្នុងសប្ដាហ៍នីមួយៗ។

ការទិញទំនិញ ឬសេវាកម្មដែលអាចនាំទៅរកភាពប្រសើររយៈពេលមធ្យម ឬវែង នៅក្នុងគុណភាពនៃជីវិត គឺមានកម្រិត។ ប្រមាណពាក់កណ្ដាលនៃការទិញរួមបញ្ចូលទាំងអស់ គឺលើសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ដូចជា ថ្លៃឈ្នួលផ្ទះ អាហារ និងការចំណាយលើសុខភាព។

ជំពូកបន្ទាប់ពិនិត្យមើលថាតើ លំនាំនៃការទិញទាំងអស់នេះ តំណាងឱ្យបុគ្គលដែលគិតថា ជីវភាពរស់នៅរបស់ពួកគេគឺគ្រប់គ្រាន់ ដូច្នេះ មិនត្រូវការទិញធំៗ ដើម្បីកែលម្អជីវភាពរបស់ពួកគេទេ ឬរបស់បុគ្គល ដែលប្រឈមមុខនឹងភាពគានតឹងផ្នែកហិរញ្ញវត្ថុ ដែលមិនទិញសម្ភារ ដោយសារតែបន្ទុកហិរញ្ញវត្ថុ។

GARMENT WORKER DIARIES

## ជំពូកទី៤៖ ការដោះស្រាយភាពតានតឹងផ្នែកហិរញ្ញវត្ថុ

កម្មករភាគច្រើនបានប្រាប់ថា ពួកគេទទួលបានស្បៀងអាហារតិចតួច ឬមិនទៀងទាត់ នៅក្នុងអំឡុងពេល១២ខែកន្លងមក ហើយថា ប្រាក់គឺជាបញ្ហាធំ នៅពេលទៅរកពេទ្យ។ នេះបង្ហាញពីកង្វះខាតប្រាក់។ ទោះបីជាយ៉ាងណាក្តី កម្មករភាគច្រើនបានសន្សំប្រាក់នៅក្នុងឆ្នាំនៃការសិក្សានេះ។ ហេតុអ្វីប្រតិមតិ? កម្មករទំនងជាកាត់បន្ថយការចំណាយដើម្បីសន្សំប្រាក់ទុកសម្រាប់គ្រាមានអាសន្ន និងសម្រាប់រយៈពេលវែង។




GARMENT WORKER DIARIES

## ការកំណត់រកភាពតានតឹង

ពុំមានការវាស់វែងពិតប្រាកដអំពីភាពតានតឹងផ្នែកហិរញ្ញវត្ថុទេ- វាពាក់ព័ន្ធនឹងបទពិសោធន៍និងបរិបទ។ កម្មករកាត់ដេរអាចមានភាពតានតឹងផ្នែកហិរញ្ញវត្ថុតិចជាងកសិករនៅក្នុងប្រទេសតែមួយ ប៉ុន្តែអាចប្រឈមនឹងភាពតានតឹងផ្នែកហិរញ្ញវត្ថុច្រើនជាងមេធាវី។ ដូច្នេះ អឹម.អេហ្វ.អូ ពិចារណាលក្ខណវិនិច្ឆ័យបួន នៅពេលពិភាក្សាបញ្ហា៖

**សូមចងចាំ**
ជំពូកទីមួយ
បង្ហាញពីទ្រព្យសម្បត្តិជាមូលដ្ឋាន ដូចជា កង្ហាល់ ចង្ក្រាន និងកៅអី គឺមានជាទូទៅ។

**ចរចងចាំ**
ជំពូកចុងក្រោយបង្ហាញថា ការទិញទាំងនេះគឺមានដោយកម្ម។

- ជីវភាពរស់នៅដែលអ្នកចូលរួមក្នុងការសិក្សា បានបញ្ជាក់ នៅពេលចាប់ផ្តើមការសិក្សា រួមទាំងអ្វីៗដូចជា កម្មសិទ្ធិទ្រព្យសម្បត្តិ និងកម្រិតភាពក្រីក្រ។
- ការទិញទំនិញ និងសេវាដើម្បីលើកកម្ពស់ជីវភាព នៅក្នុងអំឡុងពេលនៃការសិក្សា។
- ការទទួលបាន និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុរបស់អ្នកចូលរួមក្នុងការសិក្សា រួមទាំងការសន្សំប្រាក់ កម្ចី ការផ្ទេរសាច់ប្រាក់ និងការធានារ៉ាប់រង។
- ទំហំនៃការកាត់បន្ថយការទិញរបស់អ្នកចូលរួមក្នុងការសិក្សា ពិសេស ភាពចាំបាច់ជាមធ្យោបាយនៃការគ្រប់គ្រងការចំណាយរបស់ពួកគេ។

GARMENT WORKER DIARIES

# ឧបករណ៍ហិរញ្ញវត្ថុ និងភាពតានតឹងផ្នែកហិរញ្ញវត្ថុ

ឧបករណ៍ហិរញ្ញវត្ថុមានបួនប្រភេទ៖ សន្សំ កម្ចី ការផ្ទេរប្រាក់ និងការធានារ៉ាប់រង។ បុគ្គលម្នាក់ៗ ប្រើហិរញ្ញវត្ថុដើម្បីគ្រប់គ្រងលំហូរសាច់ប្រាក់របស់ពួកគេ ដោយទាញប្រាក់ចូលតាមរយៈឧបករណ៍ទាំងនេះ (ដូចជាក្នុងទម្រង់នៃការដកប្រាក់សន្សំ ឬដោយទទួលកម្ចី) ឬរុញលុយចេញ តាមរយៈឧបករណ៍ទាំងនេះ (ដូចជាក្នុងទម្រង់ជាការផ្ទេរលុយទៅសមាជិកគ្រួសារណាម្នាក់ ឬបង់បុព្វលាភធានារ៉ាប់រងជាដើម)។

បុគ្គលប្រើឧបករណ៍ហិរញ្ញវត្ថុនៅក្នុងបណ្តាញ។ កាលណាការរួមបញ្ចូលគ្នានៃឧបករណ៍និងបណ្តាញកាន់តែច្រើននោះ កញ្ចប់ឧបករណ៍គ្រប់គ្រងសាច់ប្រាក់របស់បុគ្គលមានលក្ខណៈបត់បែនកាន់តែខ្លាំង។

ការយល់ដឹងពីការរួមបញ្ចូលគ្នានៃឧបករណ៍ និងបណ្តាញនេះគឺមានសារៈសំខាន់ណាស់សម្រាប់ការយល់ដឹងពីរបៀបដែលមនុស្សគ្រប់គ្រងលុយគាត់ និងបញ្ហាផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។ ឧទាហរណ៍ ការសន្សំមានបញ្ហាតិចតួច រីឯការប្រើប្រាក់កម្ចី ដែលអាចរួមបញ្ចូលទាំងកាតព្វកិច្ចមិនផ្លូវការឬច្បាប់ដើម្បីសងវិញ គឺជាបញ្ហាធំជាង។

ការប្រើឧបករណ៍ហិរញ្ញវត្ថុ

GARMENT WORKER DIARIES

## ការសន្សំលុយ

បុគ្គលអាចសន្សំលុយខ្លួនឯងនៅផ្ទះ ឬជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ ដូចជា ធនាគារ។ ការសន្សំនៅផ្ទះគឺមានលក្ខណៈទូទៅនៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលទាប ជាងការសន្សំជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុ ដោយសារហេតុផលផ្សេងៗ។

នៅទីនេះ ក៏ដូចគ្នាផងដែរ។ ជាធម្មតា កម្មករសន្សំនៅផ្ទះ។ ភាពញឹកញាប់នៃការដាក់ប្រាក់ និងដកប្រាក់បានបង្ហាញថា កម្មករបានដាក់ប្រាក់បញ្ញើយ៉ាងធំមួយបន្ទាប់ពីបានទទួលប្រាក់បៀវត្សរ៍របស់ពួកគេ ហើយបន្ទាប់មកបានដកចេញចំនួនតិចជាងពេលដាក់ជាច្រើនដង ដើម្បីបំពេញតាមតម្រូវការចំណាយរបស់ពួកគេក្នុងអំឡុងពេលសប្តាហ៍បន្ទាប់។

ការសន្សំប្រាក់ត្រូវបានគេចាត់ទុកថាជាឧបករណ៍ហិរញ្ញវត្ថុដែលមានភាពតានតឹងទាបមួយ (ទោះបីជាការជ្រើសរើសរបៀប និងពេលវេលាដែលត្រូវចំណាយលុយសន្សំ ជារឿយៗ មានភាពតានតឹងក្តី)។



GARMENT WORKER DIARIES

## ការសន្សំជាចំណែកនៃប្រាក់ឈ្នួល

ក្រាហ្វិកខាងលើបង្ហាញពីសមាមាត្រនៃប្រាក់ចំណូលសរុបពីរោងចក្រដែលកម្មករបានសន្សំបន្ទាប់ពីការចំណាយទាំងអស់ ការផ្ទេរសាច់ប្រាក់ទៅគ្រួសារ និងមិត្តភក្តិនៅខាងក្រៅផ្ទះ និងសងបំណុល។

*កម្មករដែលរស់នៅក្នុងផ្ទះផ្ទាល់ខ្លួន ជាមួយគ្រួសាររបស់ពួកគេ អាចសន្សំប្រាក់យ៉ាងច្រើនពីប្រាក់ឈ្នួលរបស់ពួកគេខណៈដែលកម្មករដែលរស់នៅជាមួយគ្រួសារនៅក្នុងបន្ទប់ជួល ពិបាកនឹងសន្សំលុយណាស់។*

ក្រាហ្វិកខាងក្រោមបង្ហាញពីចំណែកនៃប្រាក់ចំណូលរបស់កម្មករ ដែលពួកគេអាចសន្សំបានបន្ទាប់ពី

រួមបញ្ចូលទាំងប្រភេទផ្សេងៗទៀតនៃលំហូរប្រាក់ចូល ដូចជាការផ្ទេរសាច់ប្រាក់ពីមនុស្សដែលរស់នៅក្នុងផ្ទះ។ លំហូរផ្សេងទៀតទាំងនេះ ហាក់ដូចជាសំខាន់ខ្លាំងណាស់សម្រាប់ការសន្សំរបស់កម្មករជាពិសេស សម្រាប់កម្មករនៅក្នុងប្រភេទ "គ្រួសារ និងថ្លៃជួល" ។




GARMENT WORKER DIARIES

## ការសន្សំលុយក្នុងរយៈពេលមានប្រាក់ឈ្នួល

រូបបំប្រួញនេះបង្ហាញពីចំណែកនៃរយៈពេលប្រាក់ឈ្នួល ដែលកម្មករបានរក្សាលំហូរលុយសន្សំវិជ្ជមាន (តម្លៃនៃប្រាក់បញ្ញើធំជាងប្រាក់ដក) និងចំនែកដែលកម្មករមានតុល្យភាពលុយសន្សំអវិជ្ជមាន (ប្រាក់ដកច្រើនជាងប្រាក់បញ្ញើ)។

រូបនេះបង្ហាញថា ខណៈដែលជារឿយៗ កម្មករមិនអាចសន្សំលុយបាយ ពួកគេប្រឈមនឹងលំហូលុយសន្សំអវិជ្ជមានក្នុងតែជាង ២៥ភាគរយនៃសប្តាហ៍ទាំងអស់។



GARMENT WORKER DIARIES

# ការផ្ទេរសាច់ប្រាក់

ការផ្ទេរសាច់ប្រាក់ ដែលមនុស្សម្នាក់ផ្ញើប្រាក់ទៅឱ្យមនុស្សម្នាក់ទៀត ដោយគ្មានកាតព្វកិច្ចច្បាស់លាស់ត្រូវសង ត្រូវបានគេចាត់ទុកថា មានភាពតានតឹងតិចជាងប្រាក់កម្ចី ទោះបីជាតម្រូវការសុំលុយពីមិត្តភក្តិ និងក្រុមគ្រួសារ ឬដើម្បីផ្ញើលុយដើម្បីគាំទ្រពួកគេ ជាបន្ទុកមួយក្តី។

ទិន្នន័យបង្ហាញថា កម្មករភាគច្រើនបានផ្ទេរសាច់ប្រាក់នៅក្នុងផ្ទះរបស់ពួកគេ (ហៅថា ការផ្ទេរប្រាក់អន្តរផ្ទះ ឬ IHTs)។ ភាពញឹកញាប់ និងបរិមាណ ដែលពួកគេពាក់ព័ន្ធជាមួយការផ្ទេរអន្តរផ្ទះ បង្ហាញថា កម្មករដែលរស់នៅជាមួយគ្រួសាររបស់ពួកគេ គឺជាអ្នកគ្រប់គ្រងប្រាក់សម្រាប់គ្រួសាររបស់ពួកគេ។

ចុចប៊ូតុង "ចំណែក" ដើម្បីសិក្សាបន្ថែមទៀតអំពីថាតើក្រុមនៃរបៀបរស់នៅ ប្រើការផ្ទេរសាច់ប្រាក់ដូចម្តេច។




កំណត់សម្គាល់៖ ចំនួនជាមធ្យមក្នុងមួយប្រតិបត្តិការ ជារៀលត្រូវបានផ្តល់នៅខាងលើបង្គោលនីមួយៗ។

GARMENT WORKER DIARIES

## ការផ្ទេរប្រាក់ទៅតាមចំណែកនៃការរស់នៅ




GARMENT WORKER DIARIES
អំណោយសាច់ប្រាក់ទៅតាមពេលវេលា
ការផ្ទេរសាច់ប្រាក់ខាងក្រៅផ្ទះត្រូវបានហៅថា អំណោយសាច់ប្រាក់។ ស្លាយពីមុនបង្ហាញ កម្មករ បញ្ជូនអំណោយទាំងនេះប្រមាណមួយដងក្នុងមួយខែជាមធ្យម។
ការផ្ទេរសាច់ប្រាក់ទាំងនេះបានកើតឡើងនៅក្នុង សប្តាហ៍ដូចគ្នានឹងសប្តាហ៍ដែលកម្មករទទួលបានប្រាក់ខែរបស់ពួកគេ ភាគច្រើន។
កម្មករដែលរស់នៅតែម្នាក់ឯង បញ្ជូនប្រាក់ញឹកញាប់ជាងគេបំផុត ជាពិសេសទៅម្តាយរបស់ពួកគេ នៅក្នុងភូមិនៅឯស្រុកពួកគេ ហើយជារឿយៗបញ្ជូនប្រាក់ក្នុងចំនួនច្រើន។
ទស្សនវិស័យ:
៨៣ភាគរយនៃកម្មករពេញម៉ោង បញ្ជូនអំណោយសាច់ប្រាក់ក្នុងពេលសិក្សា។ លេខកណ្តាល (មេដ្យាន) នៃអំណោយសាច់ប្រាក់គឺ ៥។
ម្នាក់ឯង & ជួលផ្ទះ
គ្រួសារ & មានជាកម្មសិទ្ធិផ្ទាល់ខ្លួន
គ្រួសារ & ជួលផ្ទះ
៥០០K
0
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនសប្តាហ៍នៃការសិក្សា
ចំនួនប្រាក់ជាមធ្យម (រៀល)


GARMENT WORKER DIARIES
អំណោយសាច់ប្រាក់ទៅតាមពេលវេលា
ម្នាក់ឯង & ជួលផ្ទះ
គ្រួសារ & មានជាកម្មសិទ្ធិផ្ទាល់ខ្លួន
គ្រួសារ & ជួលផ្ទះ
៥០០K
០
៥ ១០ ១៥ ២០ ២៥ ៣០ ៣៥ ៤០ ៤៥
ចំនួនប្រាក់ជាមធ្យម (រៀល)
អំណោយ/កាដូជាប្រាក់ដែលបានផ្តល់
ចំនួនសប្តាហ៍នៃការសិក្សា

GARMENT WORKER DIARIES

# ការប្រើកម្ចី

កម្ចីត្រូវបានគេចាត់ទុកថាជាឧបករណ៍ហិរញ្ញវត្ថុដែលមានភាពតានតឹងខ្ពស់បំផុត ពីព្រោះវារួមបញ្ចូលកាតព្វកិច្ចច្បាស់លាស់ក្នុងការសង ហើយប្រាក់ការមានន័យថា វាធ្វើឱ្យមានការចំណាយរូបិ

កម្មករប្រើកម្ចីតិចបំផុតក្នុងចំណោមឧបករណ៍ហិរញ្ញវត្ថុទាំងអស់។ ការទិញជឿ ដូចជា ទិញតាមតូបក្នុងផ្សារ គឺជាទម្លាប់ទូទៅបំផុត ហើយកើតឡើងប្រហែលបីដងក្នុងមួយឆ្នាំ។ ជាមធ្យម កម្មករខ្ចីបុលគេមួយដងក្នុងមួយឆ្នាំ។

ទោះបីជាយ៉ាងណាក្តី កម្មករដែលរស់នៅជាមួយគ្រួសារផ្ទាល់របស់ពួកគេ ខ្ចីបុលគេញឹកញាប់ជាងគេ។




កំណត់សម្គាល់: ចំនួនជាមធ្យមក្នុងមួយប្រតិបត្តិការ ជារៀល ត្រូវបានផ្តល់ខាងលើបង្គោលនីមួយៗ។

GARMENT WORKER DIARIES

## ការប្រើកម្ចី ទៅតាមចំណែកនៃការរស់នៅ



GARMENT WORKER DIARIES

# ការកាត់បន្ថយ

ផ្នែកអំពីឧបករណ៍ហិរញ្ញវត្ថុ បានបង្ហាញថាកម្មករភាគច្រើនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុដែលមានបញ្ហាតិចជាចម្បង ដូចជាការសន្សំ និងការផ្ញើរប្រាក់ ប៉ុន្តែ ជាទូទៅ កម្មករគឺជាអ្នកផ្ញើប្រាក់នៅក្រៅផ្ទះ។ ការផ្ញើរទាំងនេះបានជួយទ្រទ្រង់ដល់ក្រុមគ្រួសារក្នុងភូមិជនបទ ដែលធ្វើឱ្យពួកគេមានកាតព្វកិច្ចតានតឹងយ៉ាងខ្លាំង។

សមាសភាគមួយទៀតនៃភាពតានតឹង គឺកម្រិតដែលមនុស្សម្នាក់ៗកាត់បន្ថយភាពតម្រូវការចាំបាច់ដើម្បីគ្រប់គ្រងការចំណាយរបស់ពួកគេ។ ការកាត់បន្ថយតម្រូវការជា មូលដ្ឋាន ដូចជាអាហារឬការថែទាំសុខភាព គឺជាយន្តការដោះស្រាយភាពតានតឹងខ្លាំង ពីព្រោះពួកគេត្រូវការរាងកាយ ជាជាងកាបូបលុយ ដើម្បីស្រូបយកបញ្ហាបន្ទាន់នេះ។

ទិន្នន័យពីការអង្កេត លើសន្តិសុខស្បៀងនិងសុខភាព បញ្ជាក់ឱ្យឃើញថា កម្មករស្ថិតនៅក្រោមភាពតានតឹងប្រភេទនេះ។

ការកាត់បន្ថយ

GARMENT WORKER DIARIES

# សន្តិសុខស្បៀងរបស់កម្មករ

ការអង្កេតអំពីសន្តិសុខស្បៀង
គឺជារង្វាស់ទូទៅមួយនៃ
ការទទួលបានបរិមាណនិងប្រភេទអាហារ
ដែលមានជីវជាតិគ្រប់គ្រាន់។
លទ្ធផលពីការអង្កេត
សន្តិសុខស្បៀងដែលបានធ្វើឡើងជាមួយ
កម្មករ បានបង្ហាញថា ៥២ភាគរយ
មានស្បៀងខ្វះៗ ឬ
មិនពិតប្រាកដក្នុងអំឡុងពេល១២ខែកន្លងម
ក ("សន្តិសុខស្បៀងទាប និងទាបខ្លាំង")។
សមាសភាគចម្បងមួយនៃសំណួរអំពីសន្តិសុខ
ស្បៀងទាំងនេះ គឺកម្រិតដែលលុយជាឧបសគ្គ
មួយចំពោះការទទួលបានអាហារកាន់តែច្រើន
ឬដែលមានគុណភាពកាន់តែប្រសើរ ហើយ
លទ្ធផលទាំងនេះបង្ហាញថា
កម្មករយល់ឃើញថា
ការទទួលបានលុយគឺជាឧបសគ្គដ៏ធំមួយ។



GARMENT WORKER DIARIES

## សុខភាពបច្ចុប្បន្ន

ផ្នែកមួយទៀតដែលកម្មករច្រើនកាត់បន្ថយ គឺទៅលើការថែទាំសុខភាព -- ជាជាងស្វែងរកការថែទាំ សម្រាប់បញ្ហារ៉ាំរ៉ៃនិងស្រួចស្រាវ ពួកគេស្រូបចូល "ស្តុក" (the "shock") នៅក្នុងខ្លួនរបស់ពួកគេ។

(ការហូបតិចជាងធម្មតា ដោយសារតែពួកគេកាត់បន្ថយការចំណាយលើម្ហូបអាហារ ដើម្បីសន្សំលុយ គឺជាឧទាហរណ៍មួយទៀតនៃរាងកាយដែលស្រូបយកភាពតានតឹងផ្នែកហិរញ្ញវត្ថុ។)

អិម.អេហ្វ.អូ បានស្នើឱ្យកម្មករធ្វើការវាយតម្លៃសុខភាពខ្លួនឯង ហើយបីភាគបួននៃពួកគេបាននិយាយថា សុខភាពរបស់ពួកគេមានលក្ខណៈមធ្យមឬមិនល្អ។ ស្ទើរតែគ្មានកម្មករណាម្នាក់បាននិយាយថា ពួកគេមានសុខភាពល្អប្រសើរបំផុតឡើយ។




GARMENT WORKER DIARIES

## បញ្ហានៅក្នុងការស្វែងរកការថែទាំ

បន្ថែមពីលើនអសន្តិសុខសៀង កម្មករប្រហែលជាត្រូវកម្រិតការថែទាំសុខភាពរបស់ពួកគេ ដើម្បីជៀសវាងបញ្ហាសុខភាព។ ប្រហែល ៧០ ភាគរយនៃកម្មករ បាននិយាយថា ការទទួលបានលុយសម្រាប់ថែទាំសុខភាពគឺជាបញ្ហាធំមួយ។



GARMENT WORKER DIARIES

# គោលដៅនៃការសន្សំ

វិធីមួយទៀតដើម្បីយល់ពីភាពតានតឹងរបស់បុគ្គលម្នាក់ៗ និងការសម្រេចចិត្ត គ្រប់គ្រប្រាក់បច្ចុប្បន្នរបស់ពួកគេ គឺត្រូវយល់ពីគោលដៅរួមនិងចំណូលចិត្តរបស់ពួកគេ។ ដូច្នេះ អឹម.អេហ្វ.អូ បានសួរកម្មករនូវសំណួរពីរ៖

- តើការសន្សំប្រាក់របស់អ្នកមានគោលដៅចម្បងទីមួយដើម្បីអ្វី?
- ប្រសិនបើអ្នកបានទទួលលុយច្រើនដែលមិននឹកស្មានដល់ តើអ្នកនឹងយកលុយនោះទៅធ្វើអ្វីខ្លះ?

ចម្លើយបង្ហាញថា កម្មករភាគច្រើនចង់សន្សំលុយទុកសម្រាប់ពេលត្រូវការចាំបាច់ ដូចជាគ្រោះអាសន្ន ឬព្រឹត្តិការណ៍ជីវិតធំៗ។ ពួកគេសន្សំប្រាក់ ក្នុងគោលដៅដើម្បីកែលម្អគុណភាពជីវិតរបស់ពួកគេដែរ ដោយសង់ផ្ទះ (ដើម្បីបន្ធូរបន្ទុកជួល) វិនិយោគលើការសិក្សារបស់កូនពួកគេ និងចាប់ផ្តើមអាជីវកម្មមួយដែលពួកគេអាចឈប់ធ្វើការនៅរោងចក្រកាត់ដេរបាននៅពេលខាងមុខ។ ប្រសិនបើកម្មករទាំងនេះមានលុយច្រើនសន្ធឹកសន្ធាប់ កម្មករជាច្រើននឹងមានគោលដៅទាំងនេះ ប៉ុន្តែអ្នកខ្លះថានឹងទិញម៉ូតូផងដែរ។

គោលដៅនៃការសន្សំ | លុយច្រើនចូលមកដោយមិនបានរំពឹងទុក

GARMENT WORKER DIARIES

# គោលដៅចម្បងនៃការសន្សំលុយ









ចំណេះដឹងផ្នែកហិរញ្ញវត្ថុ; OECD

©Microfinance Opportunities. February 13, 2018.

GARMENT WORKER DIARIES

## ពិន្ទុចំណេះដឹងផ្នែកហិរញ្ញវត្ថុ




GARMENT WORKER DIARIES

## ចុងបញ្ចប់នៃសង្ខេប

អ្នកចូលរួមភាគច្រើនសន្សំប្រាក់ពីប្រាក់ចំណូលរោងចក្ររបស់ពួកគេ ក្នុងអំឡុងពេលនៃឆ្នាំដែលបានធ្វើការសិក្សា ប៉ុន្តែនេះមិនមែនមានន័យថា ពួកគេគ្មានភាពគានតឹងផ្នែកហិរញ្ញវត្ថុនោះឡើយ។ កម្មករគឺជាអ្នកគ្រប់គ្រងប្រាក់នៅក្នុងផ្ទះរបស់ពួលគេ ហើយជួនកាលគាំទ្រគ្រួសារដែលរស់នៅផ្ទះផ្សេងទៀត ដោយបញ្ជូនអំណោយជាសាច់ប្រាក់យ៉ាងច្រើន។

ទោះបីជាមានការសន្សំក្តី កម្មករបាននិយាយថា លុយគឺជាឧបសគ្គចំពោះការទិញម្ហូបអាហារ និងស្វែងរកការថែទាំសុខភាព ដែលបង្ហាញថា ការសន្សំរបស់កម្មករ មានបំណងសម្រាប់គោលដៅជាក់លាក់មួយ។ ទិន្នន័យពីការអង្កេតថ្មីៗ បានបញ្ជាក់ពីករណីនេះ-កម្មករភាគច្រើនសន្សំលុយសម្រាប់ "ពេលមានតម្រូវការ" ដូចជា គ្រោះអាសន្ន ឬព្រឹត្តិការណ៍ជីវិតធំៗ។ ពួកគេក៏សន្សំប្រាក់ក្នុងគោលដៅកែលម្អគុណភាពជីវិតរបស់ពួកគេដែរ ដូចជាសង់ផ្ទះជាដើម (ដើម្បីបន្ធូរសម្ពាធពីការជួលផ្ទះគេ) ការវិនិយោគលើការអប់រំរបស់កូនពួកគេ និងចាប់ផ្តើមអាជីវកម្មដែលនឹងជួយពួកគេឱ្យឈប់ធ្វើការក្នុងរោងចក្រកាត់ដេរ។ ប្រសិនបើ កម្មករទាំងនេះបានទទួលប្រាក់ដ៏ច្រើនដែលមិនបានរំពឹងទុក កម្មករជាច្រើននឹងប្រើវាដើម្បីសម្រេចគោលដៅទាំងនេះ ទោះបីជាប្រាក់នេះមួយចំណែកធំនឹងត្រូវបានប្រើដើម្បីទិញម្ហូបតូចក្តី។

ទិន្នន័យនេះបង្ហាញថា កម្មករទំនងជាជួបប្រទះភាពតានតឹងផ្នែកហិរញ្ញវត្ថុ-ពួកគេទិញសម្ភារៈដែលជាតម្រូវការមូលដ្ឋាន និងសន្សំសម្រាប់គោលដៅរយៈពេលវែង ឬដើម្បីការពារបញ្ហាបន្ទាន់ផ្នែកហិរញ្ញវត្ថុ។ ពួកគេអាចធ្វើការជ្រើសរើសយកការគ្រប់គ្រងលុយកាក់ពួកគេតាមវិធីនេះ ជាជាងប្រើឧបករណ៍ហិរញ្ញវត្ថុប្រកបដោយហានិភ័យ ដើម្បីជំរុញការប្រើប្រាស់បច្ចុប្បន្ន ដោយសារតែពួកគេមានចំណេះដឹងផ្នែកហិរញ្ញវត្ថុខ្ពស់។

GARMENT WORKER DIARIES

## ជំពូកទី៥៖ ជីវិតនៅក្នុងរោងចក្រ

បន្ថែមពីលើភាពតានតឹងផ្នែកផ្នែកហិរញ្ញវត្ថុ កម្មករនិយោជិតប្រឈមនឹងបរិយាកាសការងារដ៏តានតឹងក្នុងអារម្មណ៍។ អ្នកចូលរួមចំនួន ៧៧ភាគរយបានរាយការណ៍ថាមានអារម្មណ៍ថាគ្មានសុវត្ថិភាពគ្រប់ពេលនៅក្នុងរោងចក្ររបស់ពួកគេទេ រីឯ ៤0% ធ្លាប់បានឃើញភ្លើងឆេះ។ ជាងពាក់កណ្ដាលនៃអ្នកចូលរួមមានទំនុកចិត្តតិចតួចថា ពួកគេអាចប្រើប្រាស់កានច្រកចេញបន្ទាន់នៅពេលចាំបាច់។




GARMENT WORKER DIARIES

## បរិយាកាសរូបវ័ន្ត

កម្មករជាច្រើនបានរាយការណ៍ថាពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងមានសុខភាពល្អនៅក្នុងរោងចក្ររបស់ពួកគេ។ សម្រាប់អ្នកដែលមិនមានអារម្មណ៍ដូច្នេះ យល់ថាពួកគេមានការព្រួយបារម្ភអំពីសុខុមាលភាពរបស់ពួកគេ នៅពេលពួកគេទៅធ្វើការ៖

កម្មករកាត់ដេរអាយុ ២៧ឆ្នាំ នៅភ្នំពេញ បានឱ្យដឹងថា *"ខ្ញុំគិតថាសុវត្ថិភាពមិនអីទេ ប៉ុន្តែទីកន្លែងធ្វើការរបស់ខ្ញុំ មានទំហំតូចណាស់។ ច្រកចូលមានទំហំតូចចង្អៀត និងលំបាកក្នុងការដើរឆ្លងកាត់ ដូច្នេះខ្ញុំគិតថាប្រសិនបើមានគ្រោះអាសន្នណាមួយនៅក្នុងរោងចក្រនោះ យើងទាំងអស់គ្នានឹងស្លាប់។ យើងមិនអាចគេចខ្លួនបានទេ»។*

**កម្មករកាត់ដេរអាយុ ២០ឆ្នាំនៅខេត្តកំពង់ស្ពឺ បាននិយាយថា៖** *"ខ្ញុំធ្វើការជាមួយកៅស៊ូយឺត ហើយវាមានសារធាតុគីមី... វាមានក្លិនខ្លាំង...*
*ហើយយើងមិនអាចទ្រាំបានចំពោះក្លិននោះទេ។*
*គ្រប់គ្នាស្ទើរតែសន្លប់ហើយដោយសារក្លិននោះ។ ជួនកាលកម្មករពាក់ម៉ាស់ ទើបបានស្រួល។ ពួកគេមិនផ្ដល់ការងារនេះច្រើន ដល់អ្នកដែលទើបតែសម្រាលកូននោះទេ។ ពួកគេផ្ដល់ដល់ស្ត្រីទាំងនេះនូវការងារដែលមានបរិស្ថានល្អ "។-*

សុវត្ថិភាព | អគ្គិភ័យ | គុណភាពខ្យល់


GARMENT WORKER DIARIES
កម្មករមានអារម្មណ៍ថាមានសុវត្ថិភាពដូចម្ដេចដែរ
នៅក្នុងរោងចក្ររបស់ពួកគេ
១០,៥%
២៤,៥%
៦៥%
តែងតែមានអារម្មណ៍ថាមានសុវត្ថិភាព
កម្រមានអារម្មណ៍ថាមានសុវត្ថិភាព
ជួនកាល មានអារម្មណ៍ថាមានសុវត្ថិភាព
រោងចក្រគាន់តែប្រសើរនៅកម្ពុជា


GARMENT WORKER DIARIES
កម្មករមានអារម្មណ៍ថាមានសុវត្ថិភាពដូចម្ដេចដែរនៅក្នុង
រោងចក្ររបស់ពួកគេ
រោងចក្រក្រោមកម្មវិធី
“រោងចក្រគាន់តែប្រសើរនៅកម្ពុជា”
១៣%
២០%
៦៧%
រោងចក្រផ្សេងទៀត
១១%
២៧%
៦២%
តែងតែមានអារម្មណ៍ថាមានសុវត្ថិភាព
ជួនកាល មានអារម្មណ៍ថាមានសុវត្ថិភាព
កម្រមានអារម្មណ៍ថាមានសុវត្ថិភាព


GARMENT WORKER DIARIES
រោងចក្រដែលកម្មករធ្វើការក្នុងនោះ
មានចក្រចេញពេលមានអាសន្នឬទេ
១០០%
៨០%
៦០%
៤០%
២០%
0%
ចំណែកកម្មករ
ពុំមានច្រកចេញពេលមានគ្រោះអាសន្ន
មានច្រកចេញពេលមានគ្រោះអាសន្ន
រោងចក្រគាន់តែប្រសើរនៅកម្ពុជា


GARMENT WORKER DIARIES
រោងចក្រដែលកម្មករធ្វើការក្នុងនោះ មានចក្រចេញពេលមានអាសន្នឬទេ
រោងចក្រក្រោមកម្មវិធី
“រោងចក្រគាន់តែប្រសើរនៅកម្ពុជា”
រោងចក្រផ្សេងទៀត
៨%
៩៩%
៩២%
មានច្រកចេញពេលមានគ្រោះអាសន្ន
ពុំមានច្រកចេញពេលមានគ្រោះអាសន្ន


GARMENT WORKER DIARIES
រោងចក្រគាន់តែប្រសើរនៅកម្ពុជា
ទំនុកចិត្តរបស់កម្មករក្នុងការប្រើចក្រចេញពេលមានអាសន្ន
៥០%
៥០%
៣០%
២០%
១០%
0%
ចំណែកកម្មករ
មានទំនុកចិត្តខ្លាំងបំផុត
មានទំនុកចិត្តខ្លាំង
មានទំនុកចិត្តខ្លះ
មានទំនុកចិត្តតិចតួច
គ្មានទំនុកចិត្តសោះ


GARMENT WORKER DIARIES
ទំនុកចិត្តរបស់កម្មករក្នុងការប្រើចក្រចេញពេលមានអាសន្ន
៣០%
២០%
១០%
0%
ចំណែកកម្មករ
មានទំនុកចិត្តខ្លាំងបំផុត
មានទំនុកចិត្តខ្លាំង
មានទំនុកចិត្តខ្លះ
មានទំនុកចិត្តតិចតួច
គ្មានទំនុកចិត្តសោះ
រោងចក្រក្រោមកម្មវិធី 'រោងចក្រគាន់តែប្រសើរនៅកម្ពុជា'
រោងចក្រផ្សេងទៀត


GARMENT WORKER DIARIES
តើរោងចក្ររបស់កម្មករទាំងនេះ
មានប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យឬទេ?
១០០%
៨០%
៦០%
៤០%
២០%
0%
ចំណែកកម្មករ
គ្មានកណ្ដឹងប្រកាសអាសន្នអគ្គិភ័យ
មានកណ្ដឹងប្រកាសអាសន្នអគ្គិភ័យ
រោងចក្រកាន់តែប្រសើរនៅកម្ពុជា


GARMENT WORKER DIARIES
តើរោងចក្ររបស់កម្មករទាំងនេះ មានប្រព័ន្ធប្រកាសអាសន្នអគ្គិភ័យឬទេ?
រោងចក្រក្រោមកម្មវិធី
"រោងចក្រកាន់តែប្រសើរនៅកម្ពុជា"
រោងចក្រផ្សេងទៀត
១០០%
៩៨%
មានកណ្ដឹងប្រកាសអាសន្នអគ្គិភ័យ
គ្មានកណ្ដឹងប្រកាសអាសន្នអគ្គិភ័យ


GARMENT WORKER DIARIES
បានឃើញអគ្គិភ័យ
៤០%
៦០%
មិនបានឃើញអគ្គិភ័យ
បានឃើញអគ្គិភ័យ
រោងចក្រគាន់តែប្រ
សើរនៅកម្ពុជា


GARMENT WORKER DIARIES
បានឃើញអគ្គិភ័យ
រោងចក្រក្រោមកម្មវិធី
“រោងចក្រគាន់តែប្រសើរនៅកម្ពុជា”
រោងចក្រផ្សេងទៀត
៥២%
៤៨%
៣៣%
៦៧%
មិនបានឃើញអគ្គិភ័យ
បានឃើញអគ្គិភ័យ


GARMENT WORKER DIARIES
សារធាតុបំពុលខ្យល់
អិម.អេហ្វ.អូ បានសួរកម្មករថាតើពួកគេមានការព្រួយបារម្ភ ឬទេ អំពីសារធាតុបំពុលខ្យល់នៅក្នុងរោងចក្រ។ កម្មករភាគច្រើនបាននិយាយថា ពួកគេមានការព្រួយបារម្ភអំពីសារធាតុបំពុលទាំងនេះ ប៉ុន្តែ ពួកគេមានការយល់ផ្សេងគ្នាអំពី ថាតើពួកគេបានចាត់វិធានការដើម្បីព្យាយាមឬដោះស្រាយបញ្ហានេះឬទេ។
រោងចក្រគាន់តែប្រសើរនៅកម្ពុជា
២៧%
៣៨%
៣៥%
មិនព្រួយបារម្ភ
ព្រួយបារម្ភ និងពិភាក្សាជាមួយនរណាម្នាក់
ព្រួយបារម្ភ ប៉ុន្តែមិនអាចធ្វើអ្វីសោះ


GARMENT WORKER DIARIES
សារធាតុបំពុលខ្យល់
រោងចក្រក្រោមកម្មវិធី
"រោងចក្រគាន់តែប្រសើរនៅកម្ពុជា"
២៤,៥%
៤៥%
៣០,៥%
រោងចក្រផ្សេងទៀត
៣៣,៥%
២៥,៥%
៤១%
មិនព្រួយបារម្ភ
ព្រួយបារម្ភ និងពិភាក្សាជាមួយនរណាម្នាក់
ព្រួយបារម្ភ ប៉ុន្តែមិនអាចធ្វើអ្វីសោះ

GARMENT WORKER DIARIES

## ក្លិនគីមី

អិម.អេ្វ.អូ បានសួរកម្មករផងដែរអំពីថាតើពួកគេមានការព្រួយបារម្ភអំពីក្លិនគីមីនៅក្នុងរោងចក្ររបស់ពួកគេឬទេ។

កម្មករបាននិយាយថា ពួកគេមានការព្រួយបារម្ភអំពីក្លិនគីមី ប៉ុន្តែ ៤១ ភាគរយបានសម្រេចចិត្តមិនធ្វើអ្វីសោះ ដែលផ្ទុយគ្នាពី 36ភាគរយនៃកម្មករដែលបានលើកឡើងបញ្ហានេះជាមួយអ្នកខ្លះនៅក្នុង
រោងចក្រដើម្បីព្យាយាមផ្លាស់ប្តូរបញ្ហានេះ។

រោងចក្រគាន់តែប្រសើរនៅកម្ពុជា




GARMENT WORKER DIARIES

## ក្លិនគីមី

រោងចក្រក្រោមកម្មវិធី
"រោងចក្រគាន់តែប្រសើរនៅកម្ពុជា"




រោងចក្រផ្សេងទៀត




មិនព្រួយបារម្ភ
ព្រួយបារម្ភ និងពិភាក្សាជាមួយនរណាម្នាក់
ព្រួយបារម្ភ ប៉ុន្តែមិនអាចធ្វើអ្វីសោះ

GARMENT WORKER DIARIES

# បរិយាកាសអន្តរបុគ្គល

លក្ខណ: "ម៉ូតសម្លៀកបំពាក់ទំនើប" នៃឧស្សាហកម្មកាត់ដេរបានបង្កសម្ពាធយ៉ាងខ្លាំងទៅលើរោងចក្រ និងកម្មករ ដើម្បីបង្កើតផលិតផលឱ្យបានលឿន។ ជាលទ្ធផលជារឿយៗកម្មករបានរាយការណ៍ថា អ្នកត្រួតពិនិត្យរបស់ពួកគេស្រែកដាក់ពួកគេ ប្រសិនបើគេគិតថា កម្មករនឹងធ្វើការយឺតយ៉ាវ ឬធ្វើឱ្យមានកំហុសច្រើនពេក។

**កម្មករកាត់ដេរអាយុ ២៥ឆ្នាំនៅភ្នំពេញ បាននិយាយថា៖** *"គាត់និយាយថា ខ្ញុំធ្វើការយឺត ៗ ហើយនៅពេលនោះខ្ញុំមិនស្រួលខ្លួនតែគាត់បានបង្ខំខ្ញុំឱ្យធ្វើការឱ្យលឿន។ ខ្ញុំហៀបនឹងដួលសន្លប់ ហើយខ្ញុំគ្មានកម្លាំងនិយាយទេ។ ខ្ញុំខឹងខ្លាំងណាស់ ហើយខ្ញុំនិយាយមិនចេញ... ខ្ញុំយំបន្ទាប់ពីនោះ។ ខ្ញុំខឹង ខ្ញុំមិនស្រួលខ្លួន ហើយគាត់នៅតែបង្ខំខ្ញុំ។ ខ្ញុំខឹងខ្លាំងណាស់តែខ្ញុំមិនអាចធ្វើអ្វីបានសោះ»។*

ការរើសអើងប្រឆាំងនឹងកម្មករ ដែលមិនអាចធ្វើការបានយូរអង្វែងបានដោយសារតែពួកគេមានផ្ទៃពោះ ចាស់ ឬមានបញ្ហាផ្សេងទៀត គឺជាបញ្ហាដែលកើតមានជាទូទៅ ដូចជាការរើសអើងចំពោះស្ត្រីដែលចូលរួមក្នុងសកម្មភាពសហជីព។

ការរើសអើង | ការបៀតបៀន | សហជីព

GARMENT WORKER DIARIES

# ការរើសអើងនៅកន្លែងធ្វើការ

MFO
សួរកម្មករអំពីការរើសអើងជាទូទៅតាមរូបភាពផ្សេងៗនៅក្នុងរោងចក្ររបស់ពួកគេ ជាពិសេស ទាក់ទងទៅនឹងការជ្រើសរើសកម្មករឱ្យចូលធ្វើការដោយរោងចក្រ។

ទម្រង់នៃការរើសអើងជាទូទៅ គឺទៅលើស្ត្រីដែលមានផ្ទៃពោះ។ ការរើសអើងផ្អែកលើអាយុ ភេទ និងសមាជិកភាពសហជីព ក៏កើតមានជាទូទៅដែរ។

រោងចក្រកាន់តែប្រសើរនៅកម្ពុជា




GARMENT WORKER DIARIES
ការរើសអើងនៅទីកន្លែងធ្វើការ
មានផ្ទៃពោះ
អាយុ
យេនឌ័រ
សហជីព
នយោបាយ
ជាតិសាសន៍
ទំនោរផ្លូវភេទ
ពណ៌ស្បែក
សាសនា
សាសនាពីកំណើត
ស្ថានភាពអាពាហ៍ពិពាហ៍
0%
២០%
៤០%
៦០%
៨០%
១០០%
ចំណែកកម្មករ


GARMENT WORKER DIARIES
ការរើសអើងនៅទីកន្លែងធ្វើការ
មានផ្ទៃពោះ
អាយុ
យេនឌ័រ
សហជីព
នយោបាយ
ជាតិសាសន៍
ទំនោរផ្លូវភេទ
ពណ៌ស្បែក
0%
២០%
៤០%
៦០%
៨០%
១០០%
ចំណែកកម្មករ
រោងចក្រក្រោមកម្មវិធី 'រោងចក្រកាន់តែប្រសើរនៅកម្ពុជា'
រោងចក្រផ្សេងទៀត

GARMENT WORKER DIARIES

## ការបៀតបៀន

ក្នុងអំឡុងពេលនៃការសិក្សា យើងបានសួរកម្មករថាតើពួកគេធ្លាប់ទទួលរង ការរំខាន ឬការបៀតបៀន ឬការបំពានណាមួយ នៅក្នុងរោងចក្ររបស់ពួកគេឬទេ។

មួយភាគបីនៃអ្នកចូលរួម បានរាយការណ៍ពីការរំលោភបំពានផ្នែកពាក្យសម្តី ដូចជាត្រូវបានគេស្រែកដាក់ ឬក៏ប្រមាថ។ ប្រហែល ១៥%បានរាយការណ៍ថាត្រូវបានគេបង្ខំឱ្យធ្វើអ្វីមួយក្រោមការបង្ខិតបង្ខំៈ (ដូចជា ការគំរាមថាពួកគេនឹងបាត់បង់ការងារ)។ ពីរភាគរយនៃកម្មករបានរាយការណ៍អំពីការរំលោភបំពានលើរាងកាយ ដូចជាត្រូវបានគេវាយ ឬគេគប់វត្ថុដាក់ពួកគេ។




GARMENT WORKER DIARIES

## សមាជិកភាពសហជីព

រោងចក្រកាន់តែប្រសើរនៅកម្ពុជា

ទោះបីជាមានអត្ថប្រយោជន៍ជាសក្តានុពលនៃការចរចាជាសមូហភាព មានតែ ៥៨ ភាគរយនៃកម្មករប៉ុណ្ណោះ ដែល អិម.អេហ្វ.អូ បានសម្ភាសន៍ គឺជាសមាជិកនៃសហជីព។



GARMENT WORKER DIARIES

# សមាជិកភាពសហជីព




GARMENT WORKER DIARIES

# មូលហេតុដែលមិនចូលសហជីព

ក្នុងចំណោមកម្មករដែលមិនបានចូលរួមសហជីព ៤០% បាននិយាយថាពួកគេមិនបានមើលឃើញផលប្រយោជន៍ណាមួយក្នុងការចូលរួមសហជីពទេ។ ទោះជាយ៉ាងណាក៏ដោយ ២៥ភាគរយបាននិយាយថាពួកគេភ័យខ្លាចមានផលវិបាកផ្នែកច្បាប់ ហើយតិចជាង ២០ភាគរយនិយាយថាពួកគេខ្លាចបាត់បង់ការងារ។




GARMENT WORKER DIARIES
កម្មករដែលរាយការណ៍អំពីការបំភិតបំភ័យដោយរោងចក្រ
ការភ័យខ្លាចទាំងនេះមិនមែនសុទ្ធតែគ្មានមូលដ្ឋានទាំងអស់នោះទេ។ ទោះបីជាកម្មករភាគច្រើនបានរាយការណ៍ថា រោងចក្ររបស់ពួកគេមិនមានការរើសអើងចំពោះសមាជិកសហជីពនោះ កម្មករចំនួន១១ភាគរយ បាននិយាយថា មេការរោងចក្របានបំភិតបំភ័យកម្មករដោយសារតែពួកគេជាសមាជិកសហជីព។
រោងចក្រគាន់តែប្រសើរនៅកម្ពុជា
១១%
៨៩%
កម្មករដែលរោងចក្ររបស់ពួកគេបំភិតបំភ័យសមាជិកសហជីព
កម្មករដែលរោងចក្ររបស់ពួកគេមិនបំភិតបំភ័យសមាជិកសហជីព


GARMENT WORKER DIARIES
កម្មករដែលរាយការណ៍អំពីការបំភិតបំភ័យដោយរោងចក្រ
រោងចក្រក្រោមកម្មវិធី "រោងចក្រគាន់តែប្រសើរនៅកម្ពុជា"
រោងចក្រផ្សេងទៀត
១៤%
៨៦%
៨%
៩២%
កម្មករដែលរោងចក្ររបស់ពួកគេបំភិតបំភ័យសមាជិកសហជីព
កម្មករដែលរោងចក្ររបស់ពួកគេ មិនបំភិតបំភ័យសមាជិកសហជីព

GARMENT WORKER DIARIES

# អត្ថប្រយោជន៍នៃការចូលសហជីព

សម្រាប់កម្មករដែលមិនមែនជាសមាជិកសហជីព ពួកគេបានរាយការណ៍ពីចំណុចវិជ្ជមានមួយចំនួន ជាពិសេស អត្ថប្រយោជន៍កាន់តែប្រសើរ និង/ឬ ប្រាក់ឈ្នួល។ ប្រហែល ២០%នៃសមាជិកសហជីព ក៏ផ្តល់តម្លៃដល់ឆន្ទៈរបស់សហជីពក្នុងការចងក្រង និងដឹកនាំការតវ៉ា និងផ្តល់តម្លៃដល់ "កម្លាំងជាចំនួនសមាជិក" ដែលសហជីពអាចផ្តល់ផងដែរ។




GARMENT WORKER DIARIES

# ចុងបញ្ចប់នៃសង្ខេបជំពូក

អ្នកចូលរួមប្រឈមនឹងលក្ខខណ្ឌការងារលំបាក។ ប្រហែល ៣ ភាគ ៤ នៃអ្នកឆ្លើយសម្ភាសន៍បាននិយាយថាពួកគេមានអារម្មណ៍មិនមានសុវត្ថិភាពនៅក្នុងរោងចក្ររបស់ពួកគេគ្រប់ពេលវេលានោះទេ។ ពួកគេបានប្រឈមមុខនឹងកង្វល់អំពីអគ្គិភ័យដែលបង្កដោយអគ្គីសនី និងសារធាតុពុលខ្យល់។

បន្ថែមពីលើនេះទៀត មួយភាគបីនៃ កម្មករនិយោជិត បានរាយការណ៍ថាមេការរបស់ពួកគេបានស្រែកឱ្យពួកគេជាប្រចាំ រីឯអ្នកផទៃទៀតបាននិយាយថាពួកគេត្រូវបានគេបង្ខំឱ្យធ្វើការឱ្យលឿនហួសពីសមត្ថភាពរបស់ពួកគេ។ អ្នកឆ្លើយសម្ភាសន៍មួយចំនួនតូចបានរាយការណ៍ថាគេការគប់វត្ថុដាក់ពួកគេ ឬត្រូវបានគេវាយ។

ការរើសអើងនៅកន្លែងធ្វើការ គឺកើតឡើងជាទូទៅ ផងដែរ - ស្ត្រីបាននិយាយថាមេការពួកគេបានរើសអើងលើស្ត្រីក្នុងការជ្រើសរើសបុគ្គលិក ដោយសារតែពួកគេមានផ្ទៃពោះ អាយុចាស់ពេក ឬជាសមាជិកសហជីព។

GARMENT WORKER DIARIES

# ជំពូកទី៦៖ ប្រូហ្វែលរបស់កម្មករ

របាយការណ៍នេះ
បញ្ជាក់លម្អិតអំពីជីវិតរបស់កម្មករកាត់ដេរចំ
នួន ១៨៦នាក់
ដែលរស់នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែ
តើរបកគំហើញទាំងនេះឆ្លុះបញ្ចាំងទៅលើកម្ម
ករម្នាក់ៗដូចម្តេច?
ជំពូននេះនឹងស្វែងយល់ពីរឿងរ៉ាវរបស់ចិន្តា
ស្រីលក្ខណ៍ ម៉ាលី និងចាន់
ជាកម្មករកាត់ដេរបួននាក់ដែលជួបការលំបា
កនៅក្នុងជីវិតរបស់ពួកគេ។
ឈ្មោះទាំងអស់នៅក្នុងប្រូហ្វែលទាំងនេះត្រូវ
បានផ្លាស់ប្តូរពីឈ្មោះដើមរបស់ពួកគេ។
ដើម្បីការពារភាពសម្ងាត់ ស្ត្រីនៅក្នុងរូបថត
គឺមិនមែនជាស្ត្រីនៅក្នុងសាច់រឿងនេះទេ។
រូបថតផ្ទះគឺតំណាងឱ្យស្ថានភាពនៃការរស់នៅ
ជាទូទៅរបស់កម្មករកាត់ដេរ។




GARMENT WORKER DIARIES

# រឿងរបស់ចិន្តា

រឿងរបស់ចិន្តា
គឺដូចគ្នានឹងកម្មករកាត់ដេរផ្សេងទៀតនៅក្នុ
ងប្រទេសកម្ពុជាដែរ។
បន្ទាប់ពីលែងប្តីរបស់នាងកាលពីឆ្នាំ២០១១
ចិន្តាបានទៅនៅផ្ទះម្តាយនាងវិញ
ហើយធ្វើការក្នុងស្រែចម្ការវិញ។
ការងារនេះត្រូវការប្រើកម្លាំងច្រើន
ហើយមិនបានផ្តល់ដល់គ្រួសារនាងនូវប្រាក់ចំ
ណូលស្ថិតស្ថេរនោះទេ។
ដោយសារតែបញ្ហានេះហើយ
ទើបចិន្តាបានធ្វើការសម្រេចចិត្តដ៏លំបាកដើ
ម្បីមករស់នៅទីក្រុងភ្នំពេញវិញ
និងធ្វើការក្នុងឧស្សាហកម្មកាត់ដេរ។
ទោះបីជាស្ថានភាពហិរញ្ញវត្ថុរបស់នាងមានភា
ពប្រសើរវិញបន្តិចមែន
ប៉ុន្តែចិន្តាបានជួបការលំបាកថ្មីៗផងដែរ
ដោយសារតែការចំណាយរបស់នាងច្រើន
ហើយមានចំណូលតិច។

*“ការធ្វើការទីនោះគឺប្រើកម្លាំងច្រើនណាស់។
ដូច្នេះហើយបានជាខ្ញុំចង់មកធ្វើការទីនេះវិ
ញ ដើម្បីអាចរកប្រាក់បានសម្រាប់ទិញដី”។*

*“ជីវភាពខ្ញុំពិបាកខ្លាំងណាស់ (ពេលនោះ)។
សូម្បីតែម្តាយខ្ញុំសព្វថ្ងៃ គាត់នៅតែគ្មានប្តី
ហើយរស់នៅម្នាក់ឯង”។*

*“បើយើងមិនធ្វើស្រែ
យើងខ្ចីលុយពីអ្នកដទៃ
ហើយក្រោយពេលច្រូតកាត់រួច
យើងលក់ស្រូវដើម្បីសង (បំណុលគេ)។
ដូច្នេះហើយបានជាខ្ញុំ
សម្រេចចិត្តមករស់នៅនិងធ្វើការទីនេះ...”*

GARMENT WORKER DIARIES

## រឿងរបស់ចិន្តា

ចិន្តាធ្វើការជាមធ្យម ៤៥ម៉ោងក្នុងមួយសប្តាហ៍ មានម៉ោងសម្រាកចំនួន ៥ម៉ោង។ នាងបានទទួលប្រាក់ខែជិត ៨០០.០០០ រៀល ក្នុងមួយខែ ជាមធ្យម និងប្រាក់ឧបត្ថម្ភ ដែលមានជាមធ្យម ១៨.០០០ រៀលក្នុងមួយសប្តាហ៍។ ចិន្តាប្រើប្រាក់ចំណូលទាំងនេះដើម្បីទិញម្ហូបអាហារ និងសម្ភារចាំបាច់ក្នុងផ្ទះ ប៉ុន្តែជារឿយៗ ត្បិតត្បៀតទៅលើបរិមាណម្ហូបអាហារដែលនាងអាចទិញបាន ដោយដឹងថា នាងត្រូវការលុយសម្រាប់ចំណាយផ្សេងៗទៀត ។ ដោយសារតែបញ្ហានេះ ចិន្តាបានបញ្ជាក់ថា នាងមិនសូវមានសន្តិសុខស្បៀងទេ។

*"មិនសូវច្រើនទេ។ ខ្ញុំគ្រាន់តែញ៉ាំតិចជាងមុនប៉ុណ្ណោះ។ ខ្ញុំនឹងគ្មានលុយគ្រប់គ្រាន់ទេបើយើងញ៉ាំច្រើន ពីព្រោះលុយត្រូវបែងចែកដើម្បីចំណាយលើរបស់របរផ្សេងៗទៀតជាច្រើន"។*

*"ខ្ញុំនៅតែត្បិតត្បៀតការចំណាយលើម្ហូបអាហារ ពីព្រោះយើងត្រូវគិតអំពីអ្នកផ្សេងទៀតនៅក្នុងគ្រួសារ ដូចជា ម្តាយ កូន និងខ្ញុំខ្លួនឯង"។*

GARMENT WORKER DIARIES

## រឿងរបស់ចិន្តា

ចិន្តាមានកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀតដែលនាងត្រូវត្រៀមថវិកា។ ឧទាហរណ៍ ចិន្តាបានព្យាយាមផ្ញើលុយទៅម្តាយ និងកូនរបស់នាងស្ទើររាល់ខែ។ នាងត្រូវការលុយដែលត្រូវផ្ញើជាទៀងទាត់នេះចំនួន ៦៥.៨៣៣រៀលក្នុងមួយសប្តាហ៍ជាមធ្យម។ ហើយខណៈដែលចិន្តាទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីប្តីរបស់នាង នាងព្យាយាមសន្សំលុយដែលនាងរកបានខ្លះសម្រាប់ទុកប្រើប្រាស់នាពេលខាងមុខ។ ពួកគេសុបិនចង់បើកភោជនីយដ្ឋានផ្ទាល់ខ្លួនរបស់ពួកគេនៅថ្ងៃណាមួយ។ គួរឱ្យស្តាយ ពួកគេមិនបានសម្រេចគោលដៅនេះទេ នៅក្នុងអំឡុងពេលនៃការសិក្សានេះ។ ផ្ទុយទៅវិញ ចិន្តាបានបង់ប្រាក់សម្រាប់ការវះកាត់ច្រមុះនៅចុងខែវិច្ឆិកា ឆ្នាំ២០១៦។ កាលណោះ នាងពុំមានការធានារ៉ាប់រងទេ។ ជាសរុប នាងចំណាយអស់ ១.៤១៨.០០០ រៀល សម្រាប់ការវះកាត់នេះ ស្មើនឹងប្រាក់ខែនាងជិតពីរខែ។

**ប្រាក់ចំណូលនិងការចំណាយសរុបរបស់ចិន្តា**



GARMENT WORKER DIARIES

## រឿងរបស់ចិន្តា

ក្នុងនាមជាអ្នកគ្រប់គ្រងលុយដ៏វៃឆ្លាតម្នាក់ ចិន្តាបានត្បិតត្បៀតការចំណាយរបស់នាងដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុផ្សេងទៀតរបស់នាង។ ជារួម នាងអាចប្រើប្រាក់ចំណូលដែលនៅសល់របស់នាងដើម្បីទិញម្ហូបអាហារបន្ថែមទៀត ប៉ុន្តែការធ្វើបែបនេះនឹងមានន័យថា នាងនឹងមានលុយផ្ញើទៅផ្ទះតិចជាងមុន ឬសន្សំតិចជាងមុន។ ជម្រើសទីមួយនឹងធ្វើឱ្យម្តាយនិងកូនរបស់នាងជួបការលំបាក រីឯជម្រើសទីពីរនឹងធ្វើឱ្យនាងពុំមានថវិកាដើម្បីកសាងអនាគតថ្មីមួយ ឬដើម្បីការពារនាងពីគ្រោះអាសន្នផ្សេងៗ។ ដូច្នេះ ដោយមានជម្រើសពីរបីផ្សេងទៀត ចិន្តាសុខចិត្តកាត់បន្ថយម្ហូបអាហារ ដើម្បីជួយអ្នកនៅក្នុងបន្ទុករបស់នាង និងដើម្បីធ្វើការឆ្ពោះទៅរកអនាគតដែលកាន់តែប្រសើរមួយ។



GARMENT WORKER DIARIES

## រឿងរបស់ស្រីលក្ខណ៍

ស្រីលក្ខណ៍ ធំធាត់នៅក្នុងខេត្តស្វាយរៀង ដែលជាតំបន់ជនបទមួយ ចម្ងាយប្រមាណ ១០០គម ទិសអាគ្នេយ៍នៃរាជធានីភ្នំពេញ។ នៅទីនោះនាងរស់នៅជាមួយឪពុកម្តាយនិងបងប្អូនបង្កើតរបស់នាង។ មានឱកាសសេដ្ឋកិច្ចតិចតួចនៅទីនោះ ហើយគ្រួសារនាងជួបការលំបាកក្នុងជីវភាពរស់នៅ។ មានវិធីមួយដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសាររបស់នាង៖ ដូចស្ត្រីវ័យក្មេងផ្សេងទៀតជាច្រើននៅទូទាំងប្រទេសកម្ពុជាដែរ ស្រីលក្ខណ៍ អាចធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ ស្វែងរកការងារក្នុងរោងចក្រកាត់ដេរ និងផ្ញើប្រាក់មួយចំណែកមកផ្ទះដើម្បីទ្រទ្រង់គ្រួសារ។ ស្រីលក្ខណ៍បានសម្រេចចិត្តដើម្បីតាមគន្លងនេះ។ នាងបានទាក់ទងពូរបស់នាង ដែលរស់នៅក្នុងទីក្រុងភ្នំពេញ ដើម្បីជួយនាងស្វែងរកកន្លែងរស់នៅ និងធ្វើដំណើររយៈពេលពីរម៉ោងទៅកាន់ទីក្រុងដែលជាបេះដូងនៃប្រទេសកម្ពុជា។

*"(ពេលខ្ញុំចូលធ្វើការក្នុងរោងចក្រជាលើកដំបូង) ខ្ញុំរកប្រាក់បានតិចតួចណាស់ ហើយគ្រួសាររបស់ខ្ញុំមានស្ថានភាពលំបាកយ៉ាងខ្លាំង។ ដូច្នេះ ខ្ញុំក៏សម្រេចចិត្តធ្វើការដើម្បីជួយពួកគេ"។*

*"ប្រសិនបើខ្ញុំនៅស្រុកកំណើតរបស់ខ្ញុំ ខ្ញុំនឹងធ្វើស្រែ និងចិញ្ចឹមសត្វ និងដាំដំណាំ... (ខ្ញុំត្រូវតែធ្វើការក្នុងរោងចក្រដើម្បី) ជួយគ្រួសារខ្ញុំ ពីព្រោះយើងត្រូវការលុយសម្រាប់ការរស់នៅរបស់យើង ដូចជា ចំណីអាហារ អង្ករ ការព្យាបាលសុខភាព និងអ្វីៗផ្សេងទៀត"។*

GARMENT WORKER DIARIES

## រឿងរបស់ស្រីលក្ខណ៍

ជីវិតក្នុងទីក្រុងភ្នំពេញ
និងក្នុងនាមជាកម្មករកាត់ដេរម្នាក់
គឺជាជីវិតដែលខុសគ្នាខ្លាំងពីជីវិតក្នុងខេត្ត
នៅជនបទរបស់នាង។
នាងចាប់ផ្តើមធ្វើការជាអ្នកដេរនៅក្នុងរោង
ចក្រតូច ក្រៅប្រព័ន្ធមួយ ប៉ុន្តែក្រោយមក
នាងបានប្តូរទៅធ្វើការនៅរោងចក្រពីរផ្សេង
ទៀតនៅក្នុងឆ្នាំដែល MFO ធ្វើសម្ភាសនាង
ដោយធ្វើការប្តូរកន្លែងធ្វើការបន្ទាប់ពីកិច្ចស
ន្យារយៈពេលខ្លីរបស់នាងបានបញ្ចប់ទៅ។
ស្រីលក្ខណ៍ សង្ស័យថា
និយោជករបស់នាងមិនព្រមបន្តកិច្ចសន្យា
ឱ្យនាង ពីព្រោះអាយុលើស ៣០ឆ្នាំ
គេចាត់ទុកថានាងចាស់ពេកនៅក្នុងឧស្សា
ហកម្មមួយដែលភាគច្រើនជាស្ត្រីវ័យក្មេង
អាយុក្បែរ ២០ឆ្នាំ
និងស្ត្រីអាយុទើបក្រោយ២០ឆ្នាំ។

*“រោងចក្រសព្វថ្ងៃ
គេចង់បានតែមនុស្សក្មេងៗ។ អ្នកដឹងទេ
ទោះបីជាយើងចាស់មែន
តែយើងអាចធ្វើការដូចគ្នានឹងមនុស្សក្មេ
ងៗដែរ។ បន្ថែមពីលើនេះ កម្មករចាស់ៗ
(ពិបាក) ស្វែងរកការងារ។
តើពួកគេរកការងារឯណាបានធ្វើ?”*

*“នៅពេលចប់កិច្ចសន្យា (ម្ចាស់រោងចក្រ)
មិនសុំឱ្យ(យើង កម្មករចាស់) បន្តទេ
ពួកគេបញ្ចប់យើងតែម្តង។”*

GARMENT WORKER DIARIES

## រឿងរបស់ស្រីលក្ខណ៍

ទោះបីជាយ៉ាងណាក្តី ស្រីលក្ខណ៍
បន្តស្វែងរកការងារធ្វើ ដោយធ្វើការរយៈពេល
៥៣ម៉ោងក្នុងមួយសប្តាហ៍ ជាមធ្យម
និងរកប្រាក់ចំណូលបានប្រហែល
៨៥០.០០០រៀល ជាប្រាក់ខែ។
ប្រាក់ឈ្នួលទាំងនេះមានចំនួនច្រើន
ហើយត្រូវនឹងចំណាយច្រើនដែរ។
ថ្លៃជួលផ្ទះរបស់នាងគឺប្រមាណ ១១០.០០០រៀល
ក្នុងមួយខែ។ នាងចំណាយប្រហែល
២៥០.០០០រៀលក្នុងមួយខែលើម្ហូបអាហារ
និងប្រហែល
១៦០.០០០រៀលក្នុងមួយខែលើការចំណាយផ្សេង
ទៀតនៅក្នុងគ្រួសារ។ ជាមធ្យម
នាងនៅសល់ប្រាក់ចំនួនបួនដប់ម្ភៃម៉ឺនក្នុងមួ
យខែ
មុននឹងនាងត្រូវបង់កាតព្វកិច្ចហិរញ្ញវត្ថុផ្សេង
ទៀត។



GARMENT WORKER DIARIES

## រឿងរបស់ស្រីលក្ខណ៍

កាតព្វកិច្ចចម្បងគឺជាមូលហេតុដែលនាងមក
នៅទីក្រុងភ្នំពេញ៖ ស្រីលក្ខណ៍
ត្រូវការទ្រទ្រង់គ្រួសាររបស់នាង
ប៉ុន្តែនាងក៏សម្រេចបានគោលដៅផ្នែកហិរញ្ញវ
ត្ថុដ៏លំបាករបស់នាង ដោយទ្រទ្រង់ខ្លួនឯង
ផ្ញើលុយទៅផ្ទះ
និងសន្សំលុយសម្រាប់ពេលអនាគត។
នាងបានផ្ញើលុយយ៉ាងច្រើនទៅផ្ទះបានបីដង
នៅក្នុងអំឡុងពេលនៃការសិក្សានេះ
ដោយបានផ្ញើពីរដងចំនួន ៦០០.០០០រៀល
និងមួយដងចំនួន ៤០០.០០០រៀល។ ជារួម
ការផ្ទេរប្រាក់ទាំងនេះគឺស្មើនឹងលុយសន្សំជិត
ប្រាំខែ
ហើយនាងបានផ្ញើលុយកាន់តែច្រើនថែមទៀ
តនៅក្នុងអំឡុងពេលនៃការសិក្សានេះ។

ប្រាក់ចំណូលសរុប និងការចំណាយរបស់ស្រីលក្ខណ៍




GARMENT WORKER DIARIES

## រឿងរបស់ស្រីលក្ខណ៍

ការផ្ទេរលុយទៅផ្ទះ
គឺបំពេញកាតព្វកិច្ចរបស់នាងចំពោះគ្រួសារ
នាង
ប៉ុន្តែវាបានធ្វើឱ្យស្រីលក្ខណ៍ជួបការលំបាក។
នាងមានបញ្ហាពោះវៀន
ហើយការផ្ញើលុយទៅផ្ទះមានន័យថា
នាងមានលុយកាន់តែតិចសម្រាប់ស្វែងរក
ការព្យាបាល។ ដូច្នេះ ស្រីលក្ខណ៍
ដូចជាកម្មករជាច្រើនទៀតដែរ
ត្រូវបង្ខំចិត្តធ្វើការសម្រេចចិត្តដ៏លំបាក៖
តើនាងគួរបូជាសុខុមាលភាពផ្ទាល់ខ្លួននា
ងដើម្បីគ្រួសារនាង
ឬតើនាងគួរបូជាសេចក្តីត្រូវការរបស់គ្រួសា
រនាងដើម្បីធានាស្ថិរភាពសេដ្ឋកិច្ច?

*"ខ្ញុំត្រូវរក្សាទុកលុយខ្លះសម្រាប់ខ្លួនខ្ញុំ
ផ្ទាល់ និងជូនកាល សម្រាប់គ្រួសារខ្ញុំ។
ខ្ញុំត្រូវរក្សាលុយសម្រាប់ពេលខ្ញុំឈឺផង
ដែរ"។*

*"(គ្រួសារខ្ញុំ)
គ្រាន់តែផ្តល់ដំបូន្មានដល់ខ្ញុំអំពីការស
ន្សំលុយ
ហើយកុំឱ្យចាយលុយច្រើនពេក។
ពួកគេសុំឱ្យខ្ញុំចាយលុយតិចតួច។
ពួកគេព្រួយបារម្ភថា
ខ្ញុំនឹងចំណាយលុយខ្ញុំច្រើនពេក
ហើយមិនបានសន្សំលុយសម្រាប់ពេល
មានអាសន្ន"។*

GARMENT WORKER DIARIES

## រឿងរបស់ម៉ាលី

ម៉ាលី អាយុ ២៩ឆ្នាំ
នៅក្នុងពេលធ្វើការសិក្សានេះ មកភ្នំពេញ
ដែលមានចម្ងាយ ៨០គម ពីផ្ទះរបស់នាង
នៅភាគខាងត្បូង
នៅពេលនាងមានអាយុទើបតែ ១៣ឆ្នាំ។
នាងបាននិយាយថា
"ខ្ញុំមករស់នៅនិងធ្វើការនៅផ្ទះគេជាអ្នកចាំផ្ទះ។ ជាធម្មតាទេសម្រាប់យើង អ្នកក្រដែលត្រូវចេញទៅធ្វើការដើម្បីទ្រទ្រង់គ្រួសារ"
ដោយរៀបរាប់អំពីរបៀបដែលជីដូននិងម្តាយមីងរបស់នាងឱ្យនាងមកធ្វើការក្នុងទីក្រុងដើម្បីរកលុយ។
ក្នុងរយៈពេលពីរបីឆ្នាំក្រោយមកទៀត
នាងបានប្តូរការងារ
ដោយធ្វើការដំបូងជាអ្នកសម្អាតផ្ទះ
ហើយក្រោយមកទៀត
ជាអ្នករត់តុនៅឯហាងសាច់អាំងមួយក្នុងចំណោមហាងលក់សាច់អាំងជាច្រើន
នៅតាមដងផ្លូវនៃទីក្រុងនៃប្រទេសកម្ពុជា។

*"នៅពេលនោះ
ម្តាយខ្ញុំមិនសូវនៅផ្ទះទេ។
ខ្ញុំនៅជាមួយយាយខ្ញុំ
ហើយគាត់មិនមានលុយដើម្បីគាំទ្រការសិក្សារបស់ខ្ញុំទេ។ ដូច្នេះ ខ្ញុំមកភ្នំពេញ
តាមការប្រាប់ (របស់ម្តាយមីង
និងយាយខ្ញុំ)"*

*"ខ្ញុំក៏មិនចង់មក(ភ្នំពេញ) ដែរ
ប៉ុន្តែយាយខ្ញុំនិយាយថា
យើងគ្មានលុយ ដូច្នេះ
ខ្ញុំគួរតែមកទីនេះ
និងធ្វើការដើម្បីរកលុយ"។*

GARMENT WORKER DIARIES

## រឿងរបស់ម៉ាលី

នាងបានជួបប្តីរបស់នាង
និងបានរៀបការជាមួយគាត់
នៅពេលនាងទើបតែអាយុ១៨ឆ្នាំ
ហើយនាងបានឈប់ធ្វើការនៅហាងសាច់អាំងនោះ។ គាត់គឺជាអ្នករត់ម៉ូតូឌុប
ហើយនៅពេលពួកគេរស់នៅពីរនាក់ជាមួយគ្នា គាត់រកលុយបានល្មមសម្រាប់តែពីរនាក់
តែមិនគ្រប់គ្រាន់ដើម្បីឱ្យពួកគេចាកចេញពីភាពក្រីក្រឡើយ
ប៉ុន្តែគ្រាន់តែល្មមសម្រាប់តែរស់ប៉ុណ្ណោះ។ ប៉ុន្តែក្រោយមកទៀត ប្តីប្រពន្ធនេះមានកូនពីរនាក់
ហើយការចំណាយមានការកើនឡើងនៅពេលកូនគាត់តែធំ។ ក្រោយមកទៀត
ភាពតានតឹងផ្នែកហិរញ្ញវត្ថុបានជំរុញ
ឱ្យនាងទៅរកការងារធ្វើ
ហើយនាងក៏បានងាកទៅរករោងចក្រកាត់ដេរវិញ។
នាងធ្វើការជាកម្មការនីកាត់ដេរអស់រយៈពេលជាច្រើនឆ្នាំមកហើយ។



©Microfinance Opportunities. February 13, 2018. 

GARMENT WORKER DIARIES

# រឿងរបស់ម៉ាលី

ម៉ាលីបានធ្វើការនៅឯរោងចក្រកាត់ដេរមួយនៅជាងក្រុងភ្នំពេញ។ ជាមធ្យមនាងធ្វើការ ៥៣ម៉ោងក្នុងមួយសប្តាហ៍ ហើយនាងរកប្រាក់បានប្រហែល ៩០០.០០០រៀលក្នុងមួយខែ។ ប៉ុន្តែលក្ខខណ្ឌការងារគឺមិនល្អ ហើយជារឿយៗនាងមិនមានអារម្មណ៍ថាមានសុវត្ថិភាពឡើយ។ នាងបាននិយាយថា "មានភ្លើយឆេះម្តងដែរ"។ (ខ្ញុំភ័យ) វារញ៉េរញ៉ៃណាស់។ នាងក៏បានត្អូញត្អែរដែរថារោងចក្រក្តៅពេក។ "មានបង្គួច ប៉ុន្តែគេអត់បើក"។ កម្តៅនោះធ្វើឱ្យប៉ះពាល់ដល់ម៉ាលី ដោយនាងបានប្រាប់ថានាងសន្លប់ក្នុងរោងចក្រនេះ។




GARMENT WORKER DIARIES

# រឿងរបស់ម៉ាលី

ប្រាក់ខែខរបស់ម៉ាលីគឺជាជំនួយដ៏ធំចំពោះគ្រួសារពីដំបូង។ នាងនិងប្តីរបស់នាងរកប្រាក់បានគ្រប់គ្រាន់ដើម្បីរស់នៅ ប៉ុន្តែពីរឆ្នាំនៅមុនពេលការសិក្សានេះ កូនប្រុសនាងមានគ្រោះថ្នាក់ដ៏សោកនាដកម្មមួយ។ ការចំណាយលើការព្យាបាលកូនប្រុសនាងបានបង្ខំឱ្យម៉ាលីខ្ចីប្រាក់យ៉ាងច្រើនពីម្តាយក្មេករបស់នាង អ្នកធ្វើការជាមួយនាង និងអ្នកចងការប្រាក់ក្នុងភូមិ ហើយនាងគ្មានលទ្ធភាពសងបំណុលនេះបានឡើយ។ នាងបាននិយាយអំពីស្ថានភាពរបស់នាងថា "វាហាក់ដូចជាការខ្ចីជាបន្តបន្ទាប់ដូច្នោះដែរ"។ "ខ្ញុំសងម្នាក់ ហើយខ្ចីពីម្នាក់ទៀតដើម្បីសងម្នាក់ទៀត។ វានៅតែបន្តដូច្នេះរហូត"។

ប្រាក់ចំណូល និងការចំណាយសរុបរបស់ម៉ាលី



GARMENT WORKER DIARIES

## រឿងរបស់ម៉ាលី

ទីបំផុត ម៉ាលីស្ថិតក្នុងក្តីអស់សង្ឃឹម។ នាងបានសងកម្ចីគេ ១៣ដង ដែលរាល់ការសងម្តងៗមានចំនួន ៦០០.០០០រៀល នៅក្នុងអំឡុងពេលនៃការសិក្សានេះ។ ប្តីរបស់នាងរកលុយមិនបានគ្រប់គ្រាន់ដើម្បីដោះបំណុលទេ ហើយនាងទំនងជាមិនអាចរកបានការងារមួយដែលផ្តល់ប្រាក់ចំណូលលើសការងារនៅរោងចក្រនោះទេ។ អ្វីៗមិនមែនដើម្បីឱ្យមានភាពកាន់តែងាយស្រួលឆ្ពោះទៅរកចុងបញ្ចប់នៃការសិក្សាអំពី Diaries នោះទេ។

នៅក្នុងអំឡុងពេលនៃការសិក្សានេះ ម៉ាលីមានផ្ទៃពោះកូនទីបី ហើយនាងព្រួយបារម្ភអំពីថាតើនាងអាចដោះស្រាយស្ថានភាពនេះដូចម្តេច។ "(រោងចក្រអាចឱ្យខ្ញុំ) ប្រហែល ៣០០ ដុល្លារ (សម្រាប់ការឈប់សម្រាកមាតុភាព)។ វាល្អ ប៉ុន្តែវានៅតែមិនគ្រាន់។ យើងនៅតែត្រូវការបង់ថ្លៃជួលផ្ទះ ចំណីអាហារ និងរបស់របរផ្សេងៗ"។

*"(ប្តីខ្ញុំ) មិនដឹងថាខ្ញុំជំពាក់លុយគេច្រើនទេ... យើងឈ្លោះគ្នាជាច្រើន ហើយក៏មានអំពើហិង្សាខ្លះដែរកន្លងមក។ ឥឡូវនេះ គាត់ដឹង ហើយយល់ហេតុអ្វីបានជាខ្ញុំធ្វើអញ្ចឹង។ កាលនោះ គាត់អត់មានធ្វើអ្វីទេ។ ខ្ញុំត្រូវធ្វើការ ប៉ុន្តែវាមិនគ្រប់គ្រាន់។ ដូច្នេះ ខ្ញុំត្រូវខ្ចីលុយគេដើម្បីបង់ថ្លៃឈ្នួលផ្ទះ ចំណីអាហារ ការសិក្សារបស់កូន"។*

*"ប្រសិនបើ (លុយ) មិនគ្រប់ ខ្ញុំខ្ចីលុយគេម្តងទៀត ខ្ញុំសងវិញ ហើយបន្ទាប់មក ខ្ចីម្តងទៀត។ វាគឺជាបំណុលជាបន្តបន្ទាប់"។*

GARMENT WORKER DIARIES

## រឿងរបស់ចាន់

ខេត្តកំពង់ស្ពឺ ស្ថិតនៅភាគខាងកើតនៃរាជធានីភ្នំពេញ ហើយអាចត្រូវការពេលជាងមួយម៉ោង ប្រសិនបើចរាចរណ៍មមាញឹក។ នៅតាមបណ្តោយផ្លូវជាតិឆ្លងកាត់ខេត្តនេះ មានហាងជាច្រើន។ នៅតាមបណ្តោយផ្លូវជាតិនេះ ក៏មានរោងចក្រកាត់ដេរជាច្រើនផងដែរ។ សម្រាប់ស្ត្រីវ័យក្មេងនៅក្នុងតំបន់នេះ រោងចក្រកាត់ដេរផ្តល់នូវប្រភពការងារដ៏ល្អ នៅក្នុងតំបន់នានាដែលប្រជាជនធ្វើស្រែចម្ការតាមទំនៀមទម្លាប់ បើកហាងតូចៗ ធ្វើស៊ីឈ្នួលគេតាមរដូវកាល ឬធ្វើការចម្លែកៗនានាដើម្បីរស់។



GARMENT WORKER DIARIES

## រឿងរបស់ចាន់

ចាន់ ដែលទើបតែអាយុ ១៨ឆ្នាំ នៅពេល MFO បានចាប់ផ្តើមការអង្កេតនេះ បានរស់នៅទីនេះជាមួយឪពុកម្តាយរបស់នាង និងបងប្អូនបង្កើតបួននាក់នៅក្នុងផ្ទះឈើសង់ផុតពីដីមួយ។ សមាជិកគ្រួសាររបស់នាងដែលពេញវ័យទាំងអស់ សុទ្ធតែធ្វើការទាំងអស់៖ ឪពុកនាងគឺជាជាងកាត់សក់ ហើយម្តាយនាង និងបងស្រីនាងធ្វើជាកម្មករកាត់ដេរ។ ការដែលសមាជិកគ្រួសារមានការងារធ្វើបែបនេះ ធ្វើឱ្យគ្រួសាររបស់ចាន់ ទទួលបានប្រាក់ច្រើនជាងគ្រួសាររបស់កម្មករកាត់ដេរជាច្រើនទៀត។

*“ឪពុករបស់ខ្ញុំគឺជាជាងកាត់សក់នៅផ្ទះ។ ម្តាយខ្ញុំ បងស្រីខ្ញុំ និងខ្ញុំធ្វើការក្នុងរោងចក្រ។ ប្អូនខ្ញុំបីនាក់ទៀត មានអាយុ ១០ឆ្នាំ និង ៨ឆ្នាំ នៅរៀន”។*

*“យើងមិនមានលុយគ្រប់គ្រាន់ទេ។ ខ្ញុំត្រូវធ្វើការដើម្បីគាំទ្រដល់គ្រួសារ”។*

GARMENT WORKER DIARIES

## រឿងរបស់ចាន់

ទ្រព្យធនដែលរកបាន មានបង្ហាញនៅក្នុងទិន្នន័យ។ ទោះជាផ្ទះរបស់នាងស្ថិតនៅក្នុងខេត្ត ហើយគ្រួសារនាងត្រូវទៅដងទឹកពីស្ទឹងក្បែរនោះក្តី ប៉ុន្តែផ្ទះរបស់នាងមានទ្រព្យធនជាច្រើនផងដែរ។ គ្រប់គ្នាមានទូរស័ព្ទរៀងៗខ្លួន។ មានម៉ូតូពីរគ្រឿង និងកង់បីគ្រឿង ទូរទស្សន៍មួយគ្រឿង និងកង្ហាល់ជាច្រើនគ្រឿង និងចង្រ្កាន ព្រមទាំងរបស់របរផ្សេងៗទៀត។ បន្ថែមពីលើនេះ ចាន់បានប្រាប់ឱ្យដឹងថា គ្រួសារនាងតែងតែមានចំណីអាហារគ្រប់គ្រាន់សម្រាប់ហូប ហើយថា លុយសម្រាប់បញ្ហាបន្ទាន់មិនមែនជាបញ្ហាធំនោះឡើយ។



GARMENT WORKER DIARIES

## រឿងរបស់ចាន់

ទោះបីជាគ្រួសារនាងមានស្ថានភាពស្រួលបួលគួរសមមែន
ប៉ុន្តែចាន់បានសម្រេចចិត្តឈប់រៀននៅក្នុងឆ្នាំ២០១៤
ដើម្បីទៅធ្វើការក្នុងរោងចក្រកាត់ដេរដែលបានបើកនៅជិតនោះ។
ការទទួលបានការងារទីនោះគឺស្រួលទេ៖
"គេគ្រាន់តែឱ្យខ្ញុំដេរអ្វីមួយទៅ...
ហើយបន្ទាប់មក ខ្ញុំដេរ (វា)
ហើយជាប់ហ្មង"។

*"ខ្ញុំចង់(ធ្វើការក្នុងរោងចក្រកាត់ដេរ)។ អញ្ចឹងហើយបានជាខ្ញុំធ្វើការក្នុងរោងចក្រ។ ស្រីៗមិនមានជម្រើសច្រើនទេ ហើយភាគច្រើនខ្ញុំឃើញតែស្រីៗធ្វើការក្នុងរោងក្រ"។*

*"បើគ្មានរោងចក្រទេ ខ្ញុំប្រហែលជាធ្វើការនៅស្រែហើយ"។*

*"អ្នកខ្លះឱ្យតម្លៃខ្ពស់ទៅលើការសិក្សា ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំក្រ ដូច្នេះខ្ញុំត្រូវការលុយដើម្បីជួយគ្រួសារខ្ញុំ"។*

GARMENT WORKER DIARIES

## រឿងរបស់ចាន់

ចាន់ ដូចជាកម្មករកាត់ដេរផ្សេងទៀតដែរ
ធ្វើការជាច្រើនម៉ោង ប្រហែល
៥០ម៉ោងក្នុងមួយសប្តាហ៍ជាមធ្យម។
នាងរកប្រាក់បានប្រហែល ៨២០,០០០
រៀលក្នុងមួយខែ។
ទោះបីជាម៉ោងធ្វើការច្រើនមែន
ប៉ុន្តែនាងនិយាយថា
កន្លែងនាងធ្វើការមានភាពផ្សិតផ្សាលគួរសម៖
"គេមានភ្លើងអគ្គិសនី និងកាមេរ៉ាគ្រប់កន្លែង។
និយាយរួម
មានសុវត្ថិភាពខ្លាំងណាស់ក្នុងរោងចក្រ (ដែល)
ខ្ញុំធ្វើការ"។ បន្ថែមពីលើវិធានការសន្តិសុខ
នាងនិយាយថា
នាងមិនដែលឃើញមានភ្លើងឆេះនៅក្នុងរោង
ចក្រទេ ហើយជួនកាល
មានរបួសដោយគ្រោះថ្នាក់ម្ជុលម្ភាលតែប៉ុណ្ណោះ។
ក្រៅពីឧបទេវហេតុមួយដែលមេការរបស់នាង
ស្រែកឱ្យនាង ដោយសារខុសច្រើនពេក
នាងមិនដែលទទួលរងការបៀតបៀនអ្វីឡើយ។




GARMENT WORKER DIARIES
រឿងរបស់ចាន់
ដោយសារគ្រួសារនាងមានអ្នករកប្រាក់ជាច្រើន ចាន់មិនចាប់ចំណាយលុយច្រើនទេ។ នាងរួមចំណែកដល់ការចំណាយក្នុងគ្រួសារដែរ ដោយចំណាយប្រមាណពី ២០០,០០០ ទៅ ២៥០,០០០រៀល លើចំណីអាហារ និងសម្ភារប្រើប្រាស់ផ្សេងទៀត។ លុយដែលនៅសល់នាងសន្សំ ដោយសង្ឃឹមថា ថ្ងៃណាមួយនាងនឹងមានលទ្ធភាពទិញម៉ូតូដោយខ្លួនឯង គ្រឿងអលង្ការ និងសំលៀកបំពាក់ក៏ដូចជាគ្រឿងសង្ហារឹមដាក់ផ្ទះ។
ប្រាក់ចំណូល និងចំណាយសរុបរបស់ចាន់
១០M
៨M
៦M
៤M
២M
0
ចំនួនសរុប (រៀល)
ប្រាក់ចំណូល
ចំណាយ
ប្រាក់ខែ
ប្រាក់ឧបត្ថម្ភរបស់រោងចក្រ
ប្រាក់លើកទឹកចិត្តពី
ផ្ញើលុយទៅគ្រួសារ
ម្ហូបអាហារ
សំលៀកបំពាក់
ការចំណាយផ្សេងៗទៀត

GARMENT WORKER DIARIES

## មេរៀនជាបទពិសោធន៍

ទិន្នន័យពីកម្ពុជាបង្ហាញថា កម្មករ៖

១. ធ្វើការលើសម៉ោងចំនួនជាង ៤៥%ក្នុងមួយសប្តាហ៍
ហើយម៉ោងបន្ថែមនេះគឺជាផ្នែកមួយដ៏សំខាន់នៃប្រាក់ឈ្នួលរបស់ពួកគេ ដែលរួមមានប្រមាណ
១០%នៃប្រាក់ចំណូលសរុប។

២. ទទួលបានប្រាក់ឈ្នួលអប្បបរមាតាមខែនិងម៉ោង
ប៉ុន្តែប្រាក់ឈ្នួលទាំងនេះមិនគ្រប់គ្រាន់ដើម្បីលុបបំបាត់ភាពតានតឹងផ្នែកហិរញ្ញវត្ថុបានភាគ
ច្រើននោះឡើយ។

៣. ចំណាយប្រាក់ចំណូលលើចំណីអាហារ សម្ភារប្រើប្រាស់ក្នុងគ្រួសារ និងលើថ្លៃជួលផ្ទះ
សម្រាប់អ្នកដែលគ្មានផ្ទះខ្លួនឯង។ ពួកគេកម្រចំណាយលើទំនិញ
ឬសេវាកម្មដែលពាក់ព័ន្ធនឹងការកែលម្អគុណភាពជីវិតរបស់ពួកគេណាស់។

៤. មានមូលហេតុនៅទូទាំងឆ្នាំ
នៅពេលពួកគេទទួលបានចំណីអាហារដែលមានគុណភាពតិចតួចឬមិនគ្រប់គ្រាន់
ហើយជៀសវាងការស្វែងរកការថែទាំសុខភាពដោយសារតែការចំណាយផ្សេងៗ។

GARMENT WORKER DIARIES

## មេរៀនជាបទពិសោធន៍

ទោះបីជាបែបនេះក្តី ស្រ្តីទាំងនេះបានសន្សំលុយក្នុងឆ្នាំដែលបានសិក្សានេះ ហើយ
ការសម្ភាសន៍របស់ MFO ជាមួយពួកគេ បង្ហាញថា
ពួកគេកាត់បន្ថយការចំណាយលើចំណីអាហារ និងសុខភាពសម្រាប់បញ្ហាតូចតាច
ដើម្បីសន្សំលុយសម្រាប់គ្រោះអាសន្ន ឬសម្រាប់រយៈពេល។ និយាយម្យ៉ាងទៀត
កម្មករស្រូបចូលភាពតានតឹងផ្នែកហិរញ្ញវត្ថុក្នុងខ្លួនពួកគេ
ជាជាងក្នុងកាបូបលុយរបស់ពួកគេ។

ខណៈដែលវិស័យកាត់ដេរនៅកម្ពុជា មានភាពជឿនលឿនច្រើនក្នុងការកែលម្អប្រាក់ឈ្នួល
និងលក្ខខណ្ឌការងារសម្រាប់កម្មករ ទិន្នន័យនេះបង្ហាញថា
វិធានការទាំងនោះមិនគ្រប់គ្រាន់ដើម្បីលើកកម្ពស់លក្ខខណ្ឌការងារឬជីវភាពរស់នៅរបស់ពួក
គេ ដល់កម្រិតដែលបានឃើញនៅក្នុងទីក្រុងបាំងហ្គាឡូ ប្រទេសឥណ្ឌា នោះឡើយ។

©Microfinance Opportunities. February 13, 2018.


GARMENT WORKER DIARIES
ចាត់វិធានការ
ជារួម របកគំហើញដែលបង្ហាញនៅក្នុងរបាយការណ៍នេះបង្ហាញថា
កម្មករកាត់ដេរធ្វើការយូរម៉ោងសម្រាប់ប្រាក់ឈ្នួលទាប ទទួលរងភាពតានតែងផ្នែកហិរញ្ញវត្ថុ
និងលក្ខខណ្ឌការងារមិនល្អ។ ទោះបីជាមានបញ្ហាបែបនេះក្តី ពួកគេខិតខំតស៊ូ
និងជំនះឧបសគ្គទាំងនេះ
ដោយប្រកាន់ខ្ជាប់តាមក្តីសុបិននិងបំណងប្រាថ្នារបស់ពួកគេយ៉ាងជិតស្និទ្ធ។
បន្ទាប់ពីបានសិក្សាអំពីលក្ខខណ្ឌរបស់កម្មករមក យើងសង្ឃឹមថា ឥឡូវនេះ
អ្នកយល់ពីការចំណាយផ្នែកកម្លាំងកាយចិត្តរបស់មនុស្សនៃផលិតផលសំលៀកបំពាក់
និងសំលៀកបំពាក់ដែលអ្នកប្រើប្រាស់រាល់ថ្ងៃ ហើយថា
អ្នកនឹងប្រើប្រាស់ព័ត៌មាននេះដើម្បីកែលម្អជីវិតរបស់កម្មករ ដោយផ្លាស់ប្តូរទីកន្លែង
និងរបៀបដែលអ្នកទិញសំលៀក់ពាក់ ឬតាមរយៈការងារតស៊ូមតិ។ នៅពេលចាប់ផ្តើម
យើងសូមលើកទឹកចិត្តឱ្យអ្នកប្រាក់ម្ចាស់ផ្លាកឱ្យដឹងអំពីអ្វីដែលអ្នកបានសិក្សា
ដោយចុចកន្លែងនេះ ។ សូមថ្លែងអំណរគុណដល់ស្ត្រីទាំង ១៨៦នាក់
ដែលបានរួមចំណែកដល់របាយការណ៍នេះ។

កន្លែងនេះ